គណៈកម្មាធិការសង្គមស៊ីវិល Civil Society Committee

សន្និសីទសង្គមស៊ីវិលអាស៊ាន/វេទិកាប្រជាពលរដ្ឋអាស៊ាន ឆ្នាំ២០១២

ASEAN Civil Society Conference/ASEAN Peoples' Forum 2012

# សេចក្តីថ្លែងការណ៍រួម
# សន្និសីទសង្គមស៊ីវិលអាស៊ាន/វេទិកាប្រជាពលរដ្ឋអាស៊ានឆ្នាំ២០១២

៣១ មីនា ២០១២

ភ្នំពេញ កម្ពុជា

## បុព្វកថា

យើងទាំងអស់គ្នាជាប្រតិភូតំណាងឲ្យអង្គការសង្គមស៊ីវិល និងចលនាកម្មករនៅទីជនបទ និងទីក្រុង និងពលករទេសសន្តោប្រវេសន៍ កសិករ ស្ត្រី កុមារ យុវជន ចាស់ជរា ជនពិការ សហគមន៍ក្រីក្ររស់នៅក្នុងតំបន់មិនរៀបរយក្នុងទីក្រុង ប្រជាជនជនជាតិដើម ជនរងគ្រោះពីអំពើរំលោភសិទ្ធិមនុស្ស ពលករធ្វើការតាមផ្ទះ ក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា ក្រុមសកម្មជនការពារសិទ្ធិមនុស្ស និងតំណាងក្រុមផ្សេងៗទៀតជាង១២០០នាក់ បានមកជួបជុំគ្នានៅក្នុងទីក្រុងភ្នំពេញដើម្បីចូលរួមសន្និសីទសង្គមស៊ីវិលអាស៊ាន/វេទិកាប្រជាពលរដ្ឋអាស៊ានឆ្នាំ២០១២ ដើម្បីពិភាក្សាលើបញ្ហាទាំងឡាយនៅក្រោមប្រធានបទ "ប្រែក្លាយអាស៊ានទៅជាសហគមន៍ដែលយកប្រជាពលរដ្ឋជាចម្បង"។

យើងទាំងអស់គ្នាសូមធ្វើការបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់ពួកយើង ធ្វើយ៉ាងណាឲ្យអាស៊ានប្រកាន់ខ្ជាប់នូវគោលការណ៍គ្រឹះនៃប្រជាធិបតេយ្យ ការគោរពច្បាប់ សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរ អភិបាលកិច្ចល្អ ផលប្រយោជន៍ល្អបំផុតសម្រាប់កុមារ ការចូលរួមពិតប្រាកដពីគ្រប់មជ្ឈដ្ឋានប្រកបដោយអត្ថន័យ និងការអភិវឌ្ឍន៍ប្រកបដោយចិរភាពក្នុងកិច្ចខិតខំប្រឹងប្រែងសម្រេចឲ្យបាននូវការអភិវឌ្ឍន៍ និងយុត្តិធម៌សេដ្ឋកិច្ច សង្គម យេនឌ័រ និងបរិដ្ឋាន ដើម្បីនាំមកនូវសន្តិភាព និងវិបុលភាពដល់តំបន់អាស៊ានទាំងមូល។

យើងទាំងអស់គ្នាសូមសម្តែងនូវការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរចំពោះការពិត ដែលចាប់តាំងពីឆ្នាំ២០០៥មក អង្គការសង្គមស៊ីវិលបានដាក់ជូននូវអនុសាសន៍ជាបន្តបន្ទាប់ទៅមេដឹកនាំអាស៊ាន ប៉ុន្តែយើងមិនបានឃើញមានវឌ្ឍនភាពជាដុំកំភួនឡើយ។ ដូច្នេះ យើងខ្ញុំទាំងអស់គ្នា សូមលើកឡើងសារជាថ្មីនូវអនុសាសន៍របស់ពួកយើងពីវេទិកាប្រជាជនអាស៊ានឆ្នាំ២០១១ និងទទូចស្នើសុំឲ្យមេដឹកនាំអាស៊ានចាត់វិធានការយ៉ាងមានប្រសិទ្ធិភាពជាបន្ទាន់ដើម្បីអនុវត្តអនុសាសន៍ទាំងនោះ។

យើងខ្ញុំទាំងអស់គ្នាសូមលើកឡើងជាថ្មីម្តងទៀតថា ការចូលរួមរបស់ប្រជាពលរដ្ឋ និងអាស៊ានមួយដែលយកប្រជាពលរដ្ឋជាគោលពិតប្រកដ គឺជាចំណែកដ៏សំខាន់មិនអាចខ្វះបានក្នុងដំណើរការកសាងសហគមន៍អាស៊ាន។ ការយល់ដឹងកាន់តែច្រើនឡើងពីអាស៊ាន ពីកិច្ចប្រជុំនានា និងស្ថាប័នទាំងឡាយរបស់អាស៊ានគឺជាសញ្ញាជាវិជ្ជមានមួយ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ យើងទាំងអស់គ្នាសូមសម្តែងនូវការខកចិត្តយ៉ាងខ្លាំងចំពោះការរឹតត្បិតលើសិទ្ធិសេរីភាពបញ្ចេញមតិ និងការជួបប្រជុំគ្នារបស់អ្នកចូលរួមនៅក្នុងអំឡុងនៃការប្រព្រឹត្តទៅនៃអង្គសន្និសីទនិងវេទិកាឆ្នាំ២០១២នេះ។ អ្នកចូលរួមមួយចំនួនបានទទួលគំនាបមិនឲ្យចូលរួមសន្និសីទនិងវេទិកានេះ ហើយសិក្ខាសាលាតាមក្រុមស្តីពីសិទ្ធិដីធ្លី និងស្តីពីប្រទេសភូមាមិនត្រូវបានអនុញ្ញាតឲ្យធ្វើឡើយ។

យើងទាំងអស់គ្នាទទូចសុំឲ្យមេដឹកនាំអាស៊ានធានាឲ្យបានការចូលរួមរបស់ប្រជាពលរដ្ឋ និងអាស៊ានមួយដែលយកប្រជាពលរដ្ឋជាចម្បងពិតប្រាកដនៅឆ្នាំ២០១២ និងនៅប្រទេសប្រ៊ុយណេឆ្នាំ២០១៣ ក៏ដូចជាប្រទេសភូមានៅឆ្នាំ២០១៤។

យើងទាំងអស់គ្នាសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការរៀបចំអង្គពិធីក្នុងប្រទេសកម្ពុជា ដែលបានតស៊ូជំនះបន្តធ្វើសន្និសីទសង្គមស៊ីវិលអាស៊ាន និងវេទិកាប្រជាជនអាស៊ានដែលឯករាជ និងរឹងមាំនេះ និងដាក់បញ្ចូលនៅក្នុងសេចក្តីថ្លែការណ៍នេះនូវបញ្ហាចម្បងៗ និងអនុសាសន៍ជាច្រើនទៅកិច្ចប្រជុំកំពូលអាស៊ានលើកទី២០នៅកម្ពុជា។

**១. សេដ្ឋកិច្ច និងបរិដ្ឋាន**

<u>សិទ្ធិដីធ្លី</u>

កិច្ចព្រមព្រៀងដីធ្លីជាច្រើនបានរំលោភលើសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដោយមិនអើពើពីការជះឥទ្ធិពលអាក្រក់ដល់សង្គម សេដ្ឋកិច្ចនៅមូលដ្ឋាន និងបរិដ្ឋាន។ ក្នុងករណីជាច្រើន ប្រជាពលរដ្ឋដែលរស់នៅលើដី ឬអាស្រ័យផលលើដីនោះមិនត្រូវបានគេពិគ្រោះយោបល់ ឬដោះស្រាយឲ្យបានត្រឹមត្រូវ និងផ្តល់សំណងសមរម្យនោះទេ។

កិច្ចព្រមព្រៀងដីធ្លីជាច្រើនពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំ ការបំផ្លិចបំផ្លាញរបរចញ្ចឹមជីវិត និងបង្កជាវិវាទផ្សេងៗរវៀងប្រជាពលរដ្ឋមូលដ្ឋាន និងអ្នកវិនិយោគ ដែលវិវាទខ្លះនៅបន្តអូសបន្លាយរាប់ឆ្នាំ។ ការចង់បានដីពីសំណាក់ថៅកែមានអំណាច និងវិនិយោគិនបរទេសទាំងប្រញាប់ប្រញាល់បានធ្វើឲ្យគ្រួសារជាច្រើន ហើយពេលខ្លះសហគមន៍ទាំងមូលត្រូវបាត់បងផ្ទះសម្បែង និងដីធ្លីដែលពួកគេពឹងអាស្រ័យដើម្បីដាំដុះ និងរកទទួលទានចញ្ចឹមជីវិត។

លើសពីការបាត់បងដីធ្លី និងរបរចញ្ចឹមជីវិត សមាជិកសហគមន៍ដែលរងផលប៉ះពាល់ ដែលខំតស៊ូការពារផ្ទះសម្បែង និងមុខរបរចញ្ចឹមជីវិតនោះនៅបន្តប្រឈមនឹងការប្តឹងផ្តល់ទៅតុលាការពីសំណាក់វិនិយោគិនមានអំណាចទាំងនោះ។ អាជ្ញាធររដ្ឋាភិបាល ក៏ដូចជាប្រព័ន្ធតុលាការតែងខកខានមិនបានផ្តល់ការការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋទេ តែផ្ទុយទៅវិញបែរជាផ្តល់ការលើកតម្កើនដល់វិនិយោគិនមានអំណាចទាំងនោះទៅវិញ។

យើងទាំងអស់គ្នាទទួចសុំឲ្យអាស៊ាន និង/ឬ រដ្ឋជាសមាជិកចាត់វិធានការដូចខាងក្រោម:

- បញ្ឈប់ជាបន្ទាន់ការរំលោភយកដី ការបណ្តេញចេញដោយបង្ខំ និងដោយហឹង្សាលើប្រជាពលរដ្ឋរបស់ខ្លួនដែលគ្រាន់តែអនុវត្តនូវសិទ្ធិមនុស្សជាមូលដ្ឋានក្នុងការទទួលបានដីធ្លី ផ្ទះសម្បែង និងការប្រកបរបរចិញ្ចឹមជីវិត
- បង្កើនល្បឿននៃដំណើរការចុះបញ្ជីកម្មសិទ្ធិដីធ្លី និងធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធការពារសុវត្ថិភាពកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ និងត្រូវផ្តល់អាទិភាពដល់ការការពារដីធ្លី និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋរបស់ខ្លួន ជាជាងលើកតម្កើងវិនិយោគិន
- គោរពសិទ្ធិប្រើប្រាស់ដែលមានអត្ថិភាពទាំងអស់ ទោះដីនោះមាន ឬគ្មានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ផ្លូវការក្តី។ ការណ៍នេះគឺរួមបញ្ចូលទាំងដីដែលគ្រប់គ្រង និងកាន់កាប់ដោយសហគមន៍ និងដីកាន់កាប់ដោយជនជាតិដើម ឬប្រជាពលរដ្ឋដទៃទៀតដែលបានរស់នៅ និងប្រកបរបរចញ្ចឹមជីវិតនៅលើដីនោះជាច្រើនជំនាន់មកហើយ ប៉ុន្តែមិនមានឯកសារគតិយុត្តបញ្ជាក់ពីកម្មសិទ្ធិ។
- ដោះស្រាយវិវាទដីធ្លីរវាងសហគមន៍មូលដ្ឋាន និងវិនិយោគិនមានអំណាចឲ្យបានឆាប់រហ័ស និងដោយយុត្តិធម៌
- ធានាថាហេដ្ឋារចនាសម្ព័ន្ធ រួមមានសាលារៀន មន្ទីរពេទ្យ និងឱកាសការងារត្រូវបានរៀបចំជាស្រេចមុននឹងបញ្ជូនប្រជាពលរដ្ឋទៅទីតាំងថ្មី។

## បម្រែបម្រួលអាកាសធាតុ - ផលប៉ះពាល់ដល់ប្រជាជនជនជាតិដើម និងសហគមន៍អាស្រ័យផលលើព្រៃឈើ

ពលរដ្ឋក្នុងអាស៊ាន ជាពិសេសសហគមន៍ជនជាតិដើម និងសហគមន៍ពឹងផ្អែកលើអនុផលព្រៃឈើ ស្ត្រី និងកុមាររងការប៉ះពាល់ដោយផ្ទាល់ និងយ៉ាងអាក្រក់ដោយសារការប្រែប្រួលអាកាសធាតុ។ រដ្ឋាភិបាលអាស៊ានកំពុងតែចូលរួមយ៉ាងសកម្មក្នុងកិច្ចចរចារអន្តរជាតិដើម្បីជំរុញការបង្កើតយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នតាមរយៈការទប់ស្កាត់ការកាប់ និងរានព្រៃឈើ REDD+ (Reducing Emissions from Deforestation and forest Degradation Mechanism) ជាយន្តការលើកទឹកចិត្តឲ្យមានការអភិរក្ស និងគ្រប់គ្រងគម្របព្រៃឈើ និងជីវចម្រុះដោយចិរភាព។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការនេះនឹងកាន់តែមិនបានផលអ្វីទាល់តែសោះ ប្រសិនបើសហគមន៍ជនជាតិដើម និងសហគមន៍ដែលរស់អាស្រ័យផលពីព្រៃឈើមិនបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងយន្តការREDD+នៅគ្រប់កម្រិត។ លើសពីនេះទៅទៀត យន្តការ REDD+ដែលបានអនុវត្តនៅក្នុងប្រទេសសមាជិកអាស៊ានខ្លះត្រូវជួបការលំបាកដោយសារបញ្ហាអភិបាលកិច្ចទន់ខ្សោយក្នុងប្រទេសមួយចំនួនដូចជាមានអំពើពុករលួយ បក្សពួកនិយម ការរំលោភសិទ្ធិមនុស្ស ដែលរួមមានទាំងការរំលោភដោយទាហានផងដែរ។

យើងទាំងអស់គ្នាសូមលើកជាអនុសាសន៍ជូនអាស៊ាន និង/ឬរដ្ឋជាសមាជិករបស់អាស៊ានដូចខាងក្រោម:

- គោរពកាតព្វកិច្ចបម្រើផលប្រយោជន៍ឲ្យប្រជាពលរដ្ឋរបស់ខ្លួន ដែលរងផលប៉ះពាល់ដោយសារការកាប់ និងរានព្រៃឈើដោយចាត់វិធានការជាក់ស្តែង និងមានប្រសិទ្ធិភាពការពារព្រៃសហគមន៍ ដីធ្លីដែលត្រូវបានកាន់កាប់តាមប្រពៃណី ធនធានព្រៃឈើ និងធនធានធម្មជាតិ
- ផ្តល់ឱកាសឲ្យ និងគាំទ្រដល់ អង្គការសង្គមស៊ីវិលចូលរួមយ៉ាងពេញលេញក្នុងដំណើរការពិគ្រោះយោបល់ ធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តដំណើរការ REDD+
- ដោះស្រាយដោយយកចិត្តទុកដាក់ និងមានប្រសិទ្ធិភាពកត្តានាំឲ្យមានការកាប់បំផ្លាញព្រៃឈើ និងរានព្រៃតាមរយៈការសិក្សាគោលនយោបាយ និងការធ្វើកំណែទម្រង់ដែលពាក់ព័ន្ធ និងតំណាងឲ្យផលប្រយោជន៍នៃប្រជាជនរបស់ខ្លួនក្នុងកិច្ចចរចារអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)
- គោរព ការពារ និងបំពេញសិទ្ធិរបស់ជនជាតិដើមដែលរងផលប៉ះពាល់ តាមគ្រប់វិធីរួមទាំងការអនុវត្តសេចក្តីប្រកាសសកលរបស់អង្គការសហប្រជាតិស្តីពីសិទ្ធិជនជាតិដើម (UNDRIP) ជាពិសេសសិទ្ធិជនជាតិដើមភាគតិចក្នុងការទទួលបានការព្រមព្រៀងជាមុន ដោយសេរី និងមានព័ត៌មានគ្រប់គ្រាន់ និង

ការផ្តល់សិទ្ធិឲ្យជនជាតិដើមគ្រប់គ្រងព្រៃអ្នកតា និងដីធ្លីប្រពៃណីរបស់ពួកគេ ព្រមទាំងបន្តការអនុវត្តប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិជនជាតិដើម

- ធានាភាពច្បាស់លាស់ក្នុងយន្តការចែករំលែកអត្ថប្រយោជន៍ក្នុងការបន្សាំ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុ
- ដាក់បញ្ចូលការការពារយេនឌ័រក្នុងគ្រប់គោលនយោបាយ និងកម្មវិធីពាក់ព័ន្ធនឹងអាកាសធាតុ និងបរិដ្ឋាននៅថ្នាក់ជាតិ និងថ្នាក់តំបន់
- បញ្ឈប់ការបណ្តេញចេញដោយគ្មានការយល់ព្រមនិងពិគ្រោះយោបល់ជាមុន។
- ចូលរួមក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ និងតំបន់ដោយមានការចូលរួមយ៉ាងសកម្ម និងមានប្រសិទ្ធភាពពីអ្នកពាក់ព័ន្ធរួមទាំងសហគមន៍ដែលរងផលប៉ះពាល់ និងអង្គការសង្គមស៊ីវិល
- ពង្រឹងគោលនយោបាយ និងយុទ្ធសាស្ត្រដែលកំពុងអនុវត្តស្តីពីការកាត់បន្ថយគ្រោះធម្មជាតិ។

<u>ទន្លេ និងវារីអគ្គិសនី</u>

ទំនប់វារីអគ្គីសនីខ្នាតធំដែលកំពុងដំណើរការ និងកំពុងស្នើសុំសាងសង់តាមដងទន្លេមេគង្គ ទន្លេសេសាន និងតាមដៃទន្លេមេគង្គដទៃទៀតគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងប្រព័ន្ធអេកូឡូស៊ីក្នុងអាងទន្លេមេគង្គ និងទន្លេមេគង្គតាំងពីប្រភពខាងលើរហូតដល់ទំនាបសន្តខាងក្រោម។

ក្រៅពីបញ្ហាទំនប់វារីអគ្គីសនី សហគមន៍ប្រជាពលរដ្ឋតាមដងទន្លេមេគង្គ និងទន្លេសេសានប្រឈមនឹងបញ្ហាជាច្រើនទៀតដូចជាទឹកជំនន់ គ្រោះរាំងស្ងួត ឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុ ការតាំងទីលំនៅជាថ្មី ការនេសាទ បរបាញ់ និងការកាប់ឈើខុសច្បាប់ ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ការជីករុករករ៉ែ និងកំណើនប្រជាជន។ បញ្ហាទាំងអស់នេះប៉ះពាល់ដោយផ្ទាល់ទៅលើការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ ជាពិសេសបញ្ហាសន្តិសុខស្បៀង។

យើងទាំងអស់គ្នាសូមលើកជាអនុសាសន៍ជូនអាស៊ាន និង/ឬរដ្ឋជាសមាជិករបស់អាស៊ានដូចខាងក្រោម:

- លុបចោលគម្រោងសាងសង់ទំនប់សាយាប៊ូរី របស់ឡាវ និងថៃ និងពន្យាគម្រោងសាងសងទំនប់វារអគ្គីសនីសេសាន២ ជាបណ្តោះអាសន្នរង់ចាំការសិក្សាលម្អិត និងពិគ្រោះយោបល់បន្ថែមជាមួយសហគមន៍មូលដ្ឋាន
- គណកម្មការទន្លេមេគង្គគួរអនុម័ត និងអនុវត្តការលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងអនុសាសន៍របស់ខ្លួនតាមរយៈរបាយការណ៍ការវាយតម្លៃផលប៉ះពាល់បរិដ្ឋាន

- ផ្តល់នូវព័ត៌គ្រប់គ្រាន់ និងត្រឹមត្រូវស្តីពីគម្រោងសាងសង់វារីអគ្គីសនីនីមួយៗ ដើម្បីឲ្យប្រជាជនអាចពិនិត្យ និងតាមដានបាន
- ធានាឲ្យបានការផ្តល់សំណងសមរម្យដល់សហគមន៍ដែលរងផលប៉ះពាល់ដោយទំនប់វារីអគ្គីសនីដែលកំពុងដំណើរការ រួមទាំងការផ្តល់ដីកសិកម្មសម្រាប់បង្កបង្កើនផលចិញ្ចឹមជីវិត
- អាស៊ានគួរដើរតួនាទីក្នុងការជម្រុញរកដំណោះស្រាយផ្សេងសម្រាប់គម្រោងវារីអគ្គីសនីទន្លេមេគង្គ និង ការអភិវឌ្ឍន៍និងវិបុលភាពប្រកបដោយចិរភាព។

**ឧស្សាហកម្មនិស្សារណកម្ម**

ការអភិវឌ្ឍន៍ឧស្សាហកម្មនិស្សារណកម្ម ដូចជាការចម្រាញ់ប្រេង ការជីកយកត្បូងថ្ម និងរ៉ែធម្មជាតិដទៃទៀតពិតជាបានចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ាន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍បានបង្កឲ្យមានការខូចខាតបរិដ្ឋាន និងប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិមនុស្ស។ ការគ្រប់គ្រងធនធានមិនបានល្អ សមត្ថភាពមានកម្រិតក្នុងការគ្រប់គ្រងវិស័យនេះ និងបញ្ហាពុករលួយ ពាក់ព័ន្ធនឹងដំណើរការនៃការអភិវឌ្ឍន៍ឧស្សាហកម្មនិស្សារណកម្មនេះគឺជាប្រភពនៃការព្រួយបារម្ភដ៏ធំរបស់ប្រជាពលរដ្ឋ។

យើងទាំងអស់គ្នាសូមលើកជាអនុសាសន៍ជូនអាស៊ាន និង/ឬរដ្ឋជាសមាជិករបស់អាស៊ានដូចខាងក្រោមៈ

- ធ្វើយ៉ាងណាបង្កើតឲ្យមានការសិក្សាលើគុណភាព ផ្តល់ព័ត៌មានឲ្យបានត្រឹមត្រូវ ដាក់ឲ្យមានដំណើរការពិគ្រោះយោបល់ជាសាធារណៈ និងធ្វើការយកចិត្តទុកដាក់ឲ្យបានខ្ជាប់ខ្ជួន ព្រមទាំងឲ្យមានតម្លាភាព និងមានការទទួលខុសត្រូវខ្ពស់បំផុត ជាពិសេស ចំពោះគម្រោងអភិវឌ្ឍន៍ខ្នាតធំណាមួយ ដែលបង្កផលប៉ះពាល់ដល់បណ្តាសហគមន៍ នៅមុនពេលខ្លួនធ្វើសេចក្តីសម្រេចលើគម្រោងអភិវឌ្ឍ
- បង្កើតក្របខណ្ឌអាស៊ានលើឧស្សាហកម្មនិស្សារណកម្ម និងអនុម័តគំនិតផ្តួចផ្តើមឲ្យមានតម្លាភាពលើវិស័យនិស្សារណកម្ម (EITI) ដើម្បីបម្រើជាយន្តការប្រកបដោយប្រសិទ្ធភាពមួយនៅក្នុងតំបន់ ក្នុងគោលបំណងដាក់ឲ្យសាជីវកម្មទទួលខុសត្រូវ ពោលគឺ តួអង្គសាជីវកម្មទាំងនេះ ត្រូវទទួលខុសត្រូវនៅក្នុងការឆ្លើយតបទៅនឹងការរំលោភបំពានទាំងឡាយ នៅតាមទីកន្លែងដែលខ្លួនធ្វើប្រតិបត្តិការ។
- បង្កើតយន្តការឲ្យមានការចូលរួមពីពហុភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងតម្លាភាពនៅក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ
- ផ្តល់អាទិភាពលើការលើកកម្ពស់ដល់ជីវភាពស្វ័យទ្រទ្រង់ជាជាងទម្លាប់ធ្វើធុរកិច្ចពុំមែនស្វ័យទ្រង់ទ្រង់ ដែលរំលោភបំពាន និងគ្មានការទទួលខុសត្រូវ។

**ការបាត់បង់ព្រៃឈើ និងដីកសិកម្មចំពោះចំការរោបនកម្មខ្នាតធំ**

ការបន្តពង្រីករោបនកម្មចំការក្នុងបណ្តាប្រទេសអាស៊ាន ដូចជា ចំការដើមអាកាស្យាកៅស៊ូ ដូងប្រេង ល្ហុងខ្វងនិងអំពៅ បានកើតឡើងរួមជាមួយនឹងការបណ្តេញចេញដោយបង្ខំ ដោយជារឿយៗ បានធ្វើឡើងក្រោមការប្រើប្រាស់អំពើហិង្សាជ្រុល ជាហេតុបណ្តាលឲ្យគ្រួសារ និងបុគ្គលទាំងឡាយ ទទួលរងនូវការបណ្តេញចេញពីផ្ទះសម្បែង និងដីធ្លី ជាអចិន្ត្រៃយ៍ដោយពុំទទួលបានវិធានការការពារសមស្រប។ ក្នុងចំណោមស្ថានភាពធ្ងន់ធ្ងរទាំងនេះ យើងឃើញមានការធ្វើឲ្យខូចខាតយ៉ាងខ្លាំងលើបរិស្ថាន ការធ្វើឲ្យប្រជាជនក្រីក្រនៅតាមទីជនបទកាន់តែក្រីក្រ និងបាត់បង់ការរកទទួលទានតាមប្រពៃណី និងឱកាសការងារ ដោយជំនួសមកវិញជាមួយនឹងការងារដែលទទួលបានប្រាក់កម្រៃតិច ពុំមានស្ថិរភាព និងមានបទដ្ឋានការងារមិនប្រសើរ។

យើងទាំងអស់គ្នាសូមលើកជាអនុសាសន៍ជូនអាស៊ាន និង/ឬរដ្ឋជាសមាជិករបស់អាស៊ានដូចខាងក្រោម:

- បញ្ឈប់ការបណ្តេញចេញដោយបង្ខំដើម្បីផលប្រយោជន៍វិស័យកសិកម្មខ្នាតធំ។
- ត្រូវគោរពឲ្យបានពេញលេញលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ នៅគ្រប់ករណីទាំងអស់ណា ដែលគម្រោងអភិវឌ្ឍន៍បានបណ្តាលឲ្យមានការបាត់បង់កម្មសិទ្ធិបែបនេះ។ សហគមន៍ដែលទទួលរងប៉ះពាល់ត្រូវទទួលបានសំណងសមរម្យ រួមទាំង ធ្វើយ៉ាងណាឲ្យសហគមន៍មានដីកសិកម្មប្រើប្រាស់។
- បង្កើតថវិកាឲ្យបានគ្រប់គ្រាន់សម្រាប់កសិកម្មស្វ័យទ្រទ្រង់ និងបង្កើតគោលនយោបាយ និងកម្មវិធីទ្រទ្រង់កសិកម្មខ្នាតតូច ទាំងស្ត្រី បុរស និងប្រជាជនក្មេងៗ ជាពិសេស ត្រូវឲ្យមានដីនិងទឹកសម្រាប់ប្រើប្រាស់ ព្រមទាំងគ្រាប់ពូជសម្រាប់ដាំដុះ ព្រមទាំងផ្តល់ការទ្រទ្រង់លើការធ្វើកសិកម្មសរីរាង្គ ការធ្វើទីផ្សារសហករណ៍ ការទទួលបានឥណទានដែលមានការប្រាក់ទាប ហេដ្ឋារចនាសម្ព័ន្ធ និងការពង្រីកលើវិស័យកសិកម្ម និងការចូលរួមឲ្យបានពេញលេញរបស់កសិករខ្នាតតូចនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដើម្បីធានានូវសន្តិសុខស្បៀងនិងចំណីអាហារ។
- ធ្វើយ៉ាងណាឲ្យកម្មវិធី និងគោលនយោបាយអភិវឌ្ឍន៍កសិកម្មទាំងអស់ មានការគិតគូរ និងឆ្លើយតបលើបញ្ហាយេនឌ័រ។
- ពង្រីកការផ្តល់ជំនួយបច្ចេកទេសដើម្បីធ្វើឲ្យប្រសើរឡើងលើការប្រកួតប្រជែងរបស់កសិករខ្នាតតូច តាមរយៈការចែករំលែក និងការសិក្សាផ្លាស់ប្តូរបច្ចេកវិទ្យាកសិកម្មស្វ័យទ្រទ្រង់ ការបង្កើតធនាគារកសិករអាស៊ានមួយ និងក្រុមប្រឹក្សាកសិករខ្នាតតូចអាស៊ាន ដើម្បីឲ្យការចូលរួមនៅក្នុងដំណើរការអាស៊ានកើតមាន។
- បង្កើតយន្តការតាមដានដើម្បីចាប់ឲ្យសាជីវកម្មឆ្លងដែនទទួលខុសត្រូវលើតួនាទីរបស់ខ្លួនចំពោះផលិតកម្មឧស្សាហកសិកម្ម និងផលិតកម្មអាហារខ្នាតធំ សារជាតិគីមីពុល ការដកហូតដីធ្លី និងការបំផ្លាញដំណាំ រួមទាំង ការផ្តល់គោលការណ៍ណែនាំដល់រាជរដ្ឋាភិបាលអាស៊ានអំពីវិធីពង្រឹងនូវភាពស៊ីសង្វាក់គ្នារវាងគោលនយោបាយស្បៀងអាហារជាតិ និងសាកលលោក។

- ផ្តល់សច្ចាប័ន និងអនុវត្តសន្ធិសញ្ញា និងបទប្បញ្ញត្តិអន្តរជាតិ ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និងកសិកម្ម ដូចជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ កតិកានេះចែងអំពីសិទ្ធិទទួលបានស្បៀងអាហារគ្រប់គ្រាន់ និងសិទ្ធិរស់នៅសមរម្យ ដែល រួមទាំង សិទ្ធិទទួលបានគ្រាប់ពូជ និងដីធ្លីសម្រាប់កសិករខ្នាតតូច។

## និន្នាការកំលាំងពលកម្មនិងការអភិវឌ្ឍ

កម្មករជាច្រើននៅក្នុងតំបន់អាស៊ាន ត្រូវបានគេដកហូតសិទ្ធិបង្កើត និងចូលរួមសហជីព ហើយកម្មករទាំងនេះបានទទួលរងនូវការរើសអើង។ ជារឿយៗ កម្មករបំពេញការងារនៅក្នុងស្ថានភាពអាក្រក់ និងគ្រោះថ្នាក់ ដោយពុំមានប្រព័ន្ធសុវត្ថិភាពត្រឹមត្រូវ ហើយទទួលបានប្រាក់ឈ្នួលទាប តែត្រូវធ្វើការងារច្រើនម៉ោង។ ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម បានកើតឡើងនៅទូទាំងតំបន់នេះ។ គ្មានច្បាប់ជាតិ ឬ លិខិតុបករណ៍ណាមួយរបស់អាស៊ាន បានចែងគ្រប់គ្រាន់ដើម្បីការពារសិទ្ធិទាំងនេះរបស់កម្មករនោះឡើយ។

យើងទាំងអស់គ្នាសូមលើកជាអនុសាសន៍ជូនអាស៊ាន និង/ឬរដ្ឋជាសមាជិករបស់អាស៊ានដូចខាងក្រោម:

- បង្កើតឱកាសឲ្យសហជីពធ្វើជាតំណាង និងចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងតំបន់អាស៊ាន លើបញ្ហាសិទ្ធិកម្មករ។
- ធ្វើយ៉ាងណាឲ្យកម្មករទាំងអស់ទទួលបានបរិយាកាសការងារមានសុវត្ថិភាព និងសមរម្យ។
- ធានាឲ្យការគោរពសិទ្ធិមនុស្សដល់កម្មករទាំងអស់ដោយគ្មានការរើសអើង ការពារ និងបំពេញឲ្យបានជាពិសេស សិទ្ធិបង្កើត ឬ ចូលរួមសហជីព និងប្រាក់ឈ្នួលដែលអាចផ្តល់ការរស់នៅសមរម្យ សម្រាប់កម្មករគ្រប់ៗគ្នា និងក្រុមគ្រួសាររបស់ពួកគេ។
- រដ្ឋគួរផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ព្រមទាំងអនុសញ្ញា ILOដែលការពារសិទ្ធិកម្មករ។ លិខិតុបករណ៍ទាំងនេះគួរត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ជាតិ ហើយគួរត្រូវបានដាក់ឲ្យអនុវត្តឲ្យបានពេញលេញ។

## សមាហរណកម្មសេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ និងមហាអនុតំបន់ទន្លេមេគង្គ

បណ្តាប្រទេសនៅក្នុងតំបន់មេគង្គ មានប្រទេសខ្លះជាប្រទេសក្រីក្របំផុត និងប្រទេសខ្លះ ជាប្រទេសដែលទើបតែកំពុងអភិវឌ្ឍ។ រោងចក្របណ្តោះអាសន្ននានា បានធ្វើបម្លាស់ទីនៅជុំវិញតំបន់នេះ ដើម្បីស្វែងរកប្រទេសមានតម្លៃកម្លាំងពលកម្មថោកបំផុត មានការការពារកម្លាំងពលកម្មទាបបំផុត និងការលើកទឹកចិត្តខ្ពស់បំផុត។ នាពេលថ្មីៗ

ប្រទេសភូមា បានក្លាយជាមូលដ្ឋានផលិតកម្មទាក់ទាញបំផុតមួយចំពោះធុរកិច្ចទាំងឡាយណា ដែល តែងតែ "ពុំខ្វល់" ឬ កេងប្រវ័ញ្ចកម្លាំងពលកម្ម ដែលបង្ហាញឲ្យឃើញថាប្រទេសនេះផ្តល់យន្តការតិចតួច និងពុំគ្រប់ជ្រុងជ្រោយនៅក្នុង ការធានាសិទ្ធិកម្មករ។ និន្នាការនេះអាចជាការដាក់សម្ពាធលើប្រាក់ឈ្នួល និងបទដ្ឋាន ការងារនៅក្នុងតំបន់នេះទាំងមូល។

យើងសូមផ្តល់អនុសាសន៍ដល់អាស៊ាន និង/ឬ ប្រទេសជាសមាជិកអាស៊ាន ជាពិសេស បណ្តាប្រទេស នៅក្នុងអនុតំបន់មេគង្គ៖

- បង្កើតក្រមករណីកិច្ច និងគោលការណ៍សីលធម៌ធុរៈកិច្ចដែលអាចអនុវត្តបាន។
- បង្កើតប្រព័ន្ធស្តង់ដារមួយនៅក្នុងតំបន់ដើម្បីគណនាប្រាក់ជីវភាពអប្បបរមា ដែលត្រូវពិនិត្យឡើងវិញ ជារៀងរាល់ឆ្នាំ។
- ធ្វើឲ្យលក្ខខណ្ឌការងារនៅក្នុងតំបន់ក្លាយជាបទដ្ឋានលក្ខខណ្ឌការងារ។
- ផ្តល់ការបណ្តុះបណ្តាលជំនាញដល់កម្មករទាំងអស់ ជាពិសេស កម្មករដែលមានជំនាញទាប។
- បង្កើតប្រព័ន្ធមួយនៅក្នុងតំបន់ ដើម្បីការពារសិទ្ធិចូលសហជីព និងសិទ្ធិចរចារជាសមូហភាពរបស់កម្មករ។
- ប្រកាន់ខ្ជាប់នូវសិទ្ធិទទួលយុត្តិធម៌របស់កម្មករ តាមរយៈការធ្វើកំណែទម្រង់លើប្រព័ន្ធតុលាការ និង ការបង្កើនតម្លាភាព។
- ពង្រីកធាតុសំខាន់ៗឲ្យមានការហូរចូលដោយសេរីនូវពលកម្មជំនាញនៅក្នុងអាស៊ាន ដោយដាក់បញ្ចូលទាំង ប្រភេទកម្មករផ្សេងផងដែរ និង
- ឈានទៅរកការបង្កើតប្រព័ន្ធមួយនៅក្នុតំបន់សម្រាប់ការពារសិទ្ធិការងារ ដូចមានចែងនៅក្នុងសន្ធិសញ្ញា សិទ្ធិមនុស្ស និង ILO រួមទាំង បង្កើតឲ្យមានតុលាការការងារអាស៊ានផងដែរ។
-

## ២. សង្គមនិងវប្បធម៌

### សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា

ទូទាំងតំបន់អាស៊ីអគ្នេយ៍,ស្រ្តីស្រលាញ់ភេទដូចគ្នា,បុរសស្រលាញ់ភេទដូចគ្នា,អ្នកស្រលាញ់ទាំងពីរភេទ,អ្នកប្តូរភេទ,អ៊ីន ធើស៊ិកនិងឃ្វៀរ(LGBTIQ)ត្រូវបានគេចាត់ទុកថាជាប្រជាជនលំដាប់ទី២,ជនឧក្រិដ្ឋ,ត្រូវបានគេចោទថាឆ្កួត,ក្នុងករណី ខ្លះមិនត្រូវបានគេទទួលស្គាល់ថាជាមនុស្សផង។ពួកគេកើតមករស់នៅជាមួយភាពខ្មាស់អៀននិងភាពអាមាស់ឬដោយថា គេជាអ្នកណានោះ។ ការរើសអើងនិងអំពើហឹង្សាមិនត្រឹមតែពីក្រុមគ្រួសារ,មិត្តភក្តិ,សហគមន៍,និយោជកប៉ុណ្ណោះនោះទេ តែក៏ទទួលពីស្ថាបន័រដ្ឋនានាដូចជាផ្នែកនិតិបញ្ញតិជាពិសេសពីប៉ូលីសនិងអាជ្ញាធម៌សាសនា។

យើងសូមផ្តល់នូវអនុសាសន៍ថាអាស៊ាននិង/ឬរដ្ឋជាសមាជិកអាស៊ាន៖

- ដាក់បញ្ចូលនិន្នាការភេទនិងការកំណត់យែនឌ័រ(សូជី)ទៅក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន-ដោយបញ្ចូលជាពិសេសនូវសេចក្តីព្រាងពី ការកំណត់យែនឌ័រ និង និន្នាការភេទ ចូលក្នុងមាត្រា២ឮ
- លុបចោលជាបន្ទាន់នូវច្បាប់ទាំងឡាយដែលចាត់ជាបទឧក្រិដ្ឋដោយផ្ទាល់និងប្រយោលចំពោះសូជី, ហើយទទួលស្គាល់សិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នាថាជាសិទ្ធិមនុស្ស,និង ធ្វើអោយសុខដុមច្បាប់ជាតិទាំងឡាយ,គោលការណ៍និងការអនុវត្តិគោលការយ៉ក់ហ្គីយ៉ាការតា
- អនុមត័ច្បាប់ប្រឆាំងនឹងការរើសអើងទូទៅ
- ពង្រឹងនូវយន្តការថ្នាក់ជាតិនិងពិនិត្យឡើងវិញនូវយន្តការសិទ្ធិមនុស្សថ្នាក់តំបន់ដែលមានស្រាប់(ឧ.អេអាយស៊ីហេចអរ,អេស៊ីដាប៊្លឹយូស៊ី AICHR, ACWC) ដើម្បីបញ្ចូលការផ្សព្វផ្សាយនិងការពារសិទ្ធិស្មើរៗដោយមិនប្រកាន់នូវសូជីដែលពាក់ពន្ធ័និងសហគមន៍អ្នកស្រលាញ់ភេទដូចគ្នានិង
- ការចាត់ទុកការប្តូរភេទជារឿងមិនប្រក្រតីដើម្បីធ្វើអោយមានការផ្សព្វផ្សាយការរស់ជាមនុស្សសក្នុងសង្គមដែលមានលក្ខណៈសូជីផ្សេងៗពីគ្នាដោយយោងតាមបទដ្ឋានអង្គការសុខភាពពិភពលោក(WHO)។

ជនជាតិដើមភាគតិច

ជនជាត់ដើមភាគតិចនិងកូនចៅរបស់ពួកគេចែករំលែកនូវភាពអយុត្តិធម៌ជាប្រវត្តិសាស្ត្រដែលកើតឡើងជារឿយៗដោយសារតែភាពមិនសូវសំខាន់,ការមិនយោកចិត្តទុកដាក់,ការរើសអើងនិងការបង្ខំអោយដូចគ្នា។ ពួកគេមានអត្តសញ្ញាណផ្សេងៗគ្នា,ការរៀបចំខុសៗគ្នារៀងៗខ្លួន, ការចិញ្ចឹមជីវិតតាមវិធីបុរាណនិងប្រពន្ធ័គ្រប់គ្រងប្រភពធនធានក៏ដូចជាស្ថាបន័វប្បធម៏សង្គមផ្ទាល់ខ្លួនចំពាក់កណ្តាលនៃនយោបាយ,វប្បធម៏និងសេដ្ឋកិច្ចនិងទំរង់ច្បាប់។

ជនជាតិដើមភាគតិចដោយរួមមានកុមារនៅតែបន្តទទួលរងនូវការឃុំឃាំងនិងការធ្វើអាជីវកម្មទៅលើកម្មសិទ្ធិរបស់បុព្វបុរសរបស់ពួកគេដោយគ្មានការគោរពសិទ្ធិក្នុងការទទួលនិងផ្តល់ពត៏មានដោយដោយមានការយល់ព្រមនិងសេរី។ មានប្រទេសខ្លះពួកគេត្រូវបានបដេសេដ្ឋមិនផ្តល់នូវអត្តសញ្ញាណថាពួកគេជាមនុស្សផ្សេងៗពីគ្នាជាមួយសិទ្ធិពេញលេញដោយរួមមានសិទ្ធិពលរដ្ឋដែលបានច្រានពួកគេចេញពីការទទួលនូវសេវាការពារសង្គមដោយស្មើភាពគ្នាពីរដ្ឋាភិបាលឡើយ។

យើងសូមផ្តល់អនុសាសន៍ថាសហគមន៍អាស៊ាននិង/ឬរដ្ឋជាសមាជិកថា៖

- ទទួលស្គាល់ថាជនជាតិដើមភាគតិចជាមនុស្សផ្សេងពីគ្នាដោយមានសិទ្ធិពេញលេញ
- ទទួលស្គាល់សិទ្ធិជនជាតិដោមភាគតិចដោយគោរពសិទ្ធិក្នុងការទទួលនិងផ្តល់ពត៍មានដោយដោយមានការយល់ព្រមនិងសេរីដោយទាក់ទងនិងការធ្វើគំរោង, ការកែលំអនិងការអនុវត្តិការងារកម្មវិធីនិងគំរោងដែលអាចប៉ះពាល់ដល់ពួកគេ
- ជំរុញអោយរដ្ឋជាសមាជិកអាស៊ានអនុមត័យកសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចនិងនិងអនុវត្តិយ៉ាងដាច់ខាតនូវអនុសញ្ញាស្តីពីសិទ្ធិកុមារនិង
- ជ្រើសតាំងជនបង្គោលជាជនជាតិដើមភាគតិចក្នុងគណកម្មការ រដ្ឋាភិបាលចំរុះអាស៊ាននៃសិទ្ធិមនុស្ស(AICHR)និងបង្កើតអោយមានក្រុមការងារស្តីពីជនជាតិដើមភាគតិចក្នុងការធ្វើអោយមានការគោរព,ការផ្សព្វផ្សាយនិងការពារសិទ្ធិជនជាតិដើមភាគតិចនិងកុមារក្នុងសមាគមនប្រជាជាតិអាស៊ាន។

ពលករចំណាកស្រុក

កម្មករចំណាកស្រុកជារឿយៗមកពីសហគមន៍ក្រីក្រពួកគេទទួលការអប់រទាបបំផុតនិងបានណែនាំអោយបានល្អអំពីការរៀបចំខ្លួនក្នុងការងាររបស់ពួកគេដូចជាវប្បធម៏របស់ប្រទេសដែលគេនិងទៅធ្វើការនិងអ្នកដែលអាចទាក់ទងបាន។

កម្មករចំណាកស្រុកតែងតែជួបប្រទះនូវបញ្ហាឬមិនមានអ្នកទទួលស្គាល់។ ម្ចាស់ប្រទេសផ្តល់នូវសេវាគាំទ្រមានកំរិតយ៉ាងទាបសំរាប់កម្មការចំណាកស្រុកដូចជាការសិក្សាអប់រំ, សុខភាព, ការធ្វើសមាហរណ៍កម្មនិងវគ្គបណ្តុះបណ្តាលការធ្វើសមាហរណ៍កម្មឡើងវិញ។ សេវាដែលមានគឺជារឿយៗមានតែឯកសាររបស់កម្មការចំណាកស្រុកតែមិនបានពង្រាយដល់គ្រួសាររបស់គេឡើយ។

មិនត្រឹមតែមិនអាចអនុវត្តិតាមច្បាប់ជាតិឬ ស្តង់ដារអន្តរជាតិដែលការពារសិទ្ធិរបស់កម្មករចំណាចស្រុកនិងគ្រួសាររបស់គេទេតែពួកគេទុកចោលអោយមានការរំលោភបំពានសាយភាយដោយរួមមានអំពើហឹង្សានិងការដាក់ទណ្ឌកម្មដោយកំលាំងមានសមត្ថកិច្ចដែលអនុវត្តិច្បាប់និងនិយោជក។ កម្មករចំណាកស្រុកទាំងមិនផ្លូវការនិងមិនមានឯកសាររឹតតែត្រូវបានគេរំលោភបំពាននិងដាក់ទណ្ឌកម្មធ្ងន់ធ្ងរជាងហើយជាពិសេសជំរុញអោយពួកគេប្រឈមនូវការចាប់ខ្លួននិងបញ្ជូវត្រឡប់វិញ។

ស្ត្រីពលករចំណាកស្រុកជាពិសេសកម្មករបំរើតាមផ្ទះត្រូវបានគេរំលោភបំពានដោយប្រអំពើហឹង្សាយែនឌ័រដោយរួមមានការរំលោភផ្លូវភេទនិងជាកម្មករបំរើតាមផ្ទះគឺកំរត្រូវគេទទួលស្គាល់ថាជាកម្មករណាស់៖ដូច្នេះពួកគេមិនត្រូវបានការពារដោយច្បាប់ជាតិភាគច្រើន។

យើងសូមផ្តល់អនុសាសន៍ដល់សមាគមន៍អាស៊ាននិង/ឬរដ្ឋជាសមាជិក៖

- ធានាអោយអាចទទួលយកនូវយុត្តិធម៏និងយន្តការការពារចំពោះកម្មករចំណាកស្រុកដោយមិនប្រកាន់នូវស្ថានភាពណាមួយឡើយ
- ផ្តល់នូវសេវាគាំទ្រសង្គម, វគ្គបណ្តុះបណ្តាលនិងការធ្វើសមាហរណ៍កម្មកម្មវិធីសំរាប់កម្មករសំណាកស្រុកនិងគ្រួសាររបស់ពួកគេដោយមិនប្រកាន់នូវស្ថានភាពអ្វីឡើយ
- ផ្តល់សច្ចានុម័តអនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិពលករចំណាកស្រុកនិងគ្រួសាររបស់គេនិងអនុសញ្ញាអង្គការពលកម្មអន្តរជាតិការងារសមរម្យ១៨៩សំរាប់ពលករចំណាកស្រុកនិងធ្វើការកែរទំរង់ច្បាប់និងគោលនយោបាយជាតិក្នុងការទទួលស្គាល់ការងារតាមផ្ទះថាជាការងារនិងការពារសិទ្ធិរបស់ពួកគេក្រោមច្បាប់ការងារទាំងឡាយ
- ធានាថាគំរោងនៃការធ្វើសមាហរណ៍កម្មប្រជាជាតិអាស៊ីអាគ្នេយ៍ឆ្នាំ២០១៥ផ្តល់សិទ្ធិគ្រប់គ្រាន់ដល់ពលករចំណាកស្រុកទាំងអស់ទាំងស្របច្បាប់,មិនស្របច្បាប់និងគ្មានឯកសារនិងជាពិសេសការទទួលស្គាល់ពលករទាំងឡាយដែលមិនស្របច្បាប់និងគ្មានឯកសារ។
- រៀបចំចងក្រងលិខិតុបករណ៍អាស៊ានស្របច្បាប់ដែលលើកឡើងដោយគ្របដណ្តប់ពលករចំណាកស្រុកដោយមិនមានការលើកលែងនិងស្របតាមស្តង់ដារអន្តរជាតិផងដែរ
- បើកវគ្គបណ្តុះបណ្តាល/អប់រំនិយោជកអំពីសិទ្ធិរបស់ពលករចំណាកស្រុកនិងច្បាប់ពាក់ពន្ធ័និងពលកម្ម។ និយោជកមិនត្រូវជ្រើសយកកុមារមកបំរើកំលាំងពលកម្មឡើយ
- បង្កើតយន្តការដែលអាចផ្តល់នូវការទទួលបានយុត្តិធម៏សំរាប់ពលករចំណាកស្រុកដោយរួមមានសេវាបកប្រែ ជំនួយផ្នែកច្បាប់ ជំរកបណ្តោះអាសន្ន និងសិទ្ធិកម្មករក្នុងកំឡុងពេលចំណាកស្រុកនិងធ្វើការស្របច្បាប់
- ដកចេញរាល់ការអនុវត្តការធ្វើតេស្តសុខភាពដែលរួមមានហ៊ីវនិងការបញ្ជូនពលករចំណាកស្រុកត្រឡប់មកវិញដោយសារតែស្ថានភាពសុខភាព
- បង្កើតប្រពន្ធ័សុវត្ថិភាពសង្គមដែលរួមមានការធ្វើចំណាកស្រុក

- អនុវត្តិតាមសិទ្ធិពលករចំណាកស្រុកសំរាប់ការងារដែលរួមមានសិទ្ធិផ្លាស់ប្តូរនិយោជក ប្រាក់ឈ្នួល ការសំរាកសំរាលទារក និងថ្ងៃឈប់សំរាក។
- ធ្វើការអោយសកម្មដើម្បីបំបិទមិនអោយមានក្រុមហ៊ុនបញ្ជូលពលករ ភ្នាក់ងារជ្រើសរើសពលករនិងអ្នកផ្គត់ផ្គង់កំលាំងពលកម្មខុសច្បាប់
- ផ្តល់នូវលទ្ធភាពក្នុងការទទួលបាននូវសេវាសុខភាពសំរាប់កម្មករនិងគ្រួសាររបស់គេ
- ផ្សព្វផ្សាយសិទ្ធិរបស់ពលករចំណាកស្រុកក្នុងការផ្លាស់ប្តូរទីតាំងនិងសេរីភាពនៃការផ្លាស់ប្តូរ
- ធានាថាពលករចំណាកស្រុកអាចចងក្រងនិងមានសេរីភាពក្នុងការបង្កើតសមាគមន៍និងការប្រមូលផ្តុំ
- ធានាថាឧបករណ៍អាស៊ានចំពោះការផ្សព្វផ្សាយនិងការការពារសិទ្ធិពលករចំណាកស្រុកនិងការធ្វើសមាហរណ៍កម្មស្ត្រីជាពលករចំណាកស្រុកនិងគ្រួសាររបស់ពួកគេ
- ធានាថាមានជំរើសជីវិតសំរាប់ស្ត្រីនៅផ្ទះនិងក្រៅប្រទេសដូច្នេះការបង្កើតជំរើសក្នុងការផ្តល់អំណាចអោយពួកគេ
- លប់ចោលរាល់ការធ្វើតេស្តមានគភ៌និងចាត់វិធានការជាបន្ទាន់ចំពោះការបំពានដោយបញ្ចប់កិច្ចសន្យាការងារនិងបញ្ជូនស្ត្រីជាពលការមកប្រទេសកំណើតរបស់ពួកគេដោយសារស្ថានភាពមានគភ៌របស់ពួកគេនិង
- លើកទឹកចិត្តអោយប្រទេសជាសមាជិកពង្រឹងនូវគោលនយោបាយតឹងរឹងទាក់ទិននិងការចេញនូវអត្តសញ្ញាណបណ្ណ័និងការសង្កេតពីអាយុនៃការធ្វើអន្តោប្រវេស្តនិងការងារ

បញ្ហាអន្តោប្រវេស្តផ្សេងទៀត

អាពាហ៍ពិពាហ៍ជនចំណាកស្រុក អ្នកស្វែងរកសិទ្ធិជ្រកអាស្រ័យ ជនភាសខ្លួន និងគ្រួសាររបស់គេមិនបានប្រើប្រាស់សិទ្ធិដូចពលរដ្ឋដទៃទៀតទេទាំងក្នុងប្រទេសជ្រកកោននិងទាំងប្រទេសកំណើតរបស់ពួកគេ។ ក៏មានបញ្ហាអំពីការចុះសញ្ជាតិនិងការទទួលស្គាល់ជនចំណាកស្រុកដូចជាជនចំណាកស្រុកមិនស្របច្បាប់ជាដើម។

យើងសូមផ្តល់អនុសាសន៍ថាប្រជាជាតិអាស៊ាននិង/ឬរដ្ឋជាសមាជិក៖

- ធានាអោយមានសិទ្ធិចុះសញ្ជាតិដោយរួមទាំងជនចំណាកស្រុកខុសច្បាប់ផងដែរជាពិសេសសំរាប់អាពាហ៍ពិពាហ៍ជនចំណាកស្រុកនិងជនភាសខ្លួន
- ផ្តល់សិទ្ធិអាពាហ៍ពិពាហ៍ជនចំណាកស្រុករួមមានសិទ្ធិចូលជាសញ្ជាតក្រោមគំរោងសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន២០១៥

- ធានាអោយមានសិទ្ធិជាមូលដ្ឋាននិងការបំលាស់ទីដោយសុវត្ថិភាពក្នុងការសំរបសំរួលបំលាស់ទីរបស់មនុស្សនិងធានាអោយមានសិទ្ធិឯកជនភាព
- ក្នុងបរិបទជនភាសខ្លួនសំរបសំរួលការឆ្លើយតបមនុស្សធម៌ដោយរដ្ឋក្នុងការពន្យាជំលោះ(ឧ.រដ្ឋកាស៊ីនភូមា) និង
- បង្កើតយន្តការដែលផ្តល់នូវការស្វែងរកនូវយុត្តិធម៌សំរាប់ជនចំណាកស្រុកដោយរួមទាំងសេវាបកប្រែជំនួយផ្នែកច្បាប់ ជំរកបណ្តោះអាសន្ននិងសិទ្ធិជនចំណាកស្រុកអោយស្នាក់នៅនិងធ្វើការក្នុងដំណើការគាំទ្រផ្នែកច្បាប់

សិទ្ធិកុមារ

បញ្ហានិងកង្វល់របស់កុមារមិនត្រូវបានដាក់ជាអាទិភាពឡើយនិងមិនត្រូវបានលើកមកធ្វើការសំរេចចិត្តដោយអាស៊ាន។អវត្តមាននៃច្បាប់ការពារកុមារក្នុងប្រទេសជាច្រើនធ្វើអោយមានការកើនឡើងជាបន្តបន្ទាប់ចំពោះការទទួលយកនូវអំពើហឹង្សាសង្គមគ្រប់ទំរង់ដូចជាទណ្ឌកម្មជាដើម។

កុមារក្នុងតំបន់ប្រឈមមុខបញ្ហាជាច្រើនដូចជាអំពើហឹង្សា ការរើសអើង កង្វះខាតនៃការផ្តល់យុត្តិធម៌ និងយន្តការគាំពារកុមាររងគ្រោះដោយការរំលោភសិទ្ធិ។ អវត្តមាននូវយន្តការចូលរួមដោយប្រសិទ្ធិភាពក្នុង ACWC កុមារក៏ទទួលរងនូវទំរង់នៃការប៉ះពាល់ផ្សេងៗគ្នានិងតំរូវការជាក់លាក់ព្រមទាំងការការពារមិនត្រូវបានយកមកប្រើឡើយ។

យើងសូមផ្តល់អនុសាសដល់អាស៊ាននិង/ឬរដ្ឋជាសមាជិក៖

- ធានាថាច្បាប់មានដាក់ការការពារនិងផ្សព្វផ្សាយសិទ្ធិកុមារត្រូវបានរិតបន្តឹងអោយបានខ្លាំងខ្លា
- រៀបចំឬក្នុងករណីខ្លះដូចជាការកំណត់អាណត្តិនូវយន្តការឆ្លើយតបចំពោះបញ្ហាដែលមានស្រាប់ត្រូវតែត្រូវបានលើកឡើងពីសិទ្ធិកុមារ
- បង្កើតយន្តការនិងដំណើរការដែលធានាថាកុមារមានឪកាសចូលរួមពេញលេញក្នុងវេទិកាកុមារអាស៊ានដែលអាចអោយភ្ជាប់ក្រុមកុមារនិងត្រូវបានផ្តល់ពត៏មាននិងគោរពតាមគោលការណ៍ណែនាំដែលអាចទទួលយកបាន
- ផ្តល់ជំនួសជាបន្ទាន់ដល់ប្រទេសជាសមាជិកអាស៊ានក្នុងកំឡុងវិបត្តិគ្រោះទឹកជំនន់និងធ្វើសមាហរណ៍កម្មចំណេះដឹងចំពោះជំនួយបន្ទាន់និងរៀបចំសំរាប់កុមារក្នុងកម្មវិធីសាលានិងតាមរយៈសារពត៏មាន

- ផ្តល់នូវប្រភពពិតប្រាកដដែលធ្វើអោយកុមារដែលមានប្រវត្តិខុសៗអាចអនុវត្តិសិទ្ធិរបស់ពួកគេដោយមិនមានការរើសអើងឡើយ
- រៀបចំបង្កើតនូវផែនការសកម្មភាពអាស៊ានសំរាប់កុមារដោយមានរៀបចំថវិកាសំរាប់អនុវត្តការងារផងដែរ
- ចំរុញអោយមានការប្រកាសជំរើសទី៣នៃអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារចំពោះទំរង់ច្បាប់ទំនាក់ទំនងនិងបង្កើតយន្តការតវ៉ាឯករាជ្យអាស៊ានផ្អែកលើគោលការសិទ្ធិកុមារ
- បង្កើតយន្តការពត៏មានត្រឡប់ដោយរាក់ទាក់ក្នុងការទទួលនិងឆ្លើយតបតាមការផ្តល់អនុសាសនិងការចែករំលែកដល់កុមារ
- បង្កើនថវិកាជំនួយដល់សកម្មភាពនិងការផ្តួចផ្តើមនិង
- ជំរុញច្បាប់ជនពិកាសំខាន់គឺកុមារទាំងផ្លូវចិត្តនិងភាពអវិជ្ជា

យុវជន

យុវជនជួបប្រទះនូវបញ្ហាការបង្រៀនមិនមានគុណភាពពេញលេញ ឧបករណ៍អប់រំនៅមានកំរិត ឳកាសអប់រំមិនទាន់មានសមភាពសំរាប់ក្រុមមនុស្សសំខាន់ៗ ក្រុមងាយរងគ្រោះនិងភាគតិច និងកង្វះខាត កម្មវិធីដែលផ្តល់អាហារបំប៉នដល់យុវវ័យ ការផ្តល់ឳកាសដែលមានកំណត់និងតឹងរឹងសំរាប់សេរីភាព នៃការបញ្ចេញយោបលនិងការចូលរួមរបស់យុវជនដ៏ពេញលេញ ជំលោះនិងអំពើហឹង្សា មិនផ្តល់នូវពត៏មានដែលទាក់ទងនិងសុខភាពផ្លូវភេទនិងសុខភាពបន្តពូជនិងសិទ្ធិនិងពត៏មានគ្រប់ជ្រុងជ្រោយអំពីផ្លូវភេទសំរាប់យុវជន។

យើងសូមផ្តល់អនុសាសន៍ដល់សហគមន៍អាស៊ាននិង/ឬរដ្ឋជាសមាជិក៖

- បង្កើតស្តង់ដារអប់រំអតិបរមាថ្នាក់តំបន់(យ៉ាងហោចណាស់ត្រូវដាក់ថវិកាជាតិ២០%សំរាប់ការអប់រំ)ដែលធានាថាការអនុវត្តពេញលេញនៃ “ការអប់រំសំរាប់ទាំងអស់គ្នា”
- បង្កើតនិងអនុវត្តទំរង់ច្បាប់និងយន្តការដែលផ្អែកលើសិទ្ធិមនុស្សដើម្បីការពារយុវវ័យជាពិសេសយុវវ័យក្នុងស្រុកនិងពលករចំណាកស្រុកនិងយុវវ័យផ្នែកនយោបាយ ក្រុមនិងចលនា
- បញ្ចូលម៉ូឌុលអំពីការសិក្សាសន្តិភាព(ដោយមានការចូលរួមយ៉ាងពេញលេញពីយុវវ័យ) នៅគ្រប់លំដាប់នៃការសិក្សា
- ផ្តល់និងចាត់នូវអទិភាពនូវសកលវិទ្យាល័យអំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជនិងសិទ្ធិដែលសិទ្ធិមនុស្សជាពិសេសការលើកឡើងពីភាពផ្សេងៗគ្នានៃភេទនិងការកំណត់យែនឌ័រ

- បង្កើតអោយមានថវិកាសំរប់ជួយលើគ្រោះធម្មជាតិដែលលើកក្នុងពីតំរូវការរបស់កុមារនិងយុវជនដែលទទួលផលប៉ះពាល់ដោយធម្មជាតិនិងការបង្កើតដោយមនុស្សនិង
- ទទួលស្គាល់យ៉ាងលេញទាំងការខិតខំថ្នាក់ជាតិនិងថ្នក់តំបន់ចំពោះកុមារនិងយុវជនតាមរយៈពត៌មានយុវជនអាស៊ាននិងក្រុមតាមដានក្នុងការឆ្លើយតបនិងការវាយតំលៃបញ្ហាគ្រប់កំរិត

សិទ្ធិទទួលបានការអប់រំប្រកដដោយគុណភាព

ក្នុងឆ្នាំ២០០៩នៅអាស៊ីអាគ្នាយ៍និងបាស៊ីហ្វិកវិទ្យុយុវជននិងយុវវ័យដែលភាពគ្មានការងារធ្វើមានរហូតដល់៥.១ គឺអាក្រក់បំផុតលើពិភពលោក

យើងសូមផ្តល់អនុសាសន៍ដល់សមាគមន៍អាស៊ាននិងប្បរដ្ឋសមាជិកថាៈ

- ការអនុវត្តការអប់រំដោយពេញលេញសំរប់គោលដោះទី៣ដោយធានាថាមានប្រភពគ្រប់គ្រាន់ទាំងក្នុងនិងក្រៅប្រពន្ឋ័និងការបណ្តោះបណ្តាល និងបំណិនជីវិតជាពិសេសអ្នកក្រ កុមារ យុវជន ស្ត្រីចំណាកស្រុកនិងមនុស្សដែលមិនមានទីលំនៅ
- ធានាថាវិជ្ជាជីវនៃការបង្រៀនត្រូវបានផ្តល់តំលៃនិងបត់បែនក្នុងនោះមានប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗដោយបង្កើតនូវស្តង់ដារប្រាក់ខែអតិបរមាសំរាប់គ្រូបង្រៀន
- លើកយកស្តង់ដារការអប់រំនិងការកែសំរួលគុណភាពអប់រំដែលមានការពាក់ពន្ឋ័ វិទ្យាសាស្ត្រ មានន័យខ្លឹមសារនិងឆ្លើយតមនិងយែនឌ័រ
- លើកឡើងពីបញ្ហាដែលទាក់ទងនិងសមភាពយែនឌ័រក្នុងការអប់ដោយផ្តោតលើកុមារានិងកុមារី ការពាក់ពន្ឋ័ផ្សេងៗអំពីការអប់រំចំពោះសហគមន៍ដែលមិនសូវទទួលបាននូវផលប្រយោជន៍ ដាច់ស្រយាល នៅជនបទនិងតំបន់ភ្នំនិងជនជាតិដើមភាគតិច
- បង្ហើបពីបញ្ហាយែនឌ័រក្នុងការថែទាំកុមារនិងការអភិវឌ្ឍន៍ដោយរួមមានការចូលរួមរបស់ឪពុកក្នុងការថែទាំកុមារនិងការឆ្លើយតបយែនឌ័រសំរាប់ជនចំណាកស្រុកនិងក្មេងមិនមានការទទួលស្គាល់ដោយរដ្ឋ
- លើកពីបញ្ហាភាពមិនប្រក្រតីចំពោះកុមារដោយផ្អែកលើការវិភាគយែនឌ័រ
- អនុវត្តគោលការណ៍ដែលពង្រឹងការគិតរបស់គ្រួសារចំពោះតំលៃនៃកូនស្រីនិងពង្រីកឱកាសសំរាប់ស្ត្រីវ័យក្មេង។គាំទ្រប្រពន្ឋ័ដែលផ្តល់ដល់ស្ត្រីក្នុងការចូលរួមដែលត្រូវបានធ្វើសមាហរណ៍កម្មកម្មវិធីអក្ខរកម្ម
- បង្កើតនិងអនុវត្តស្តង់ដារសាលាសំរាប់កុមារដែលមានភាពរាក់ទាក់ដោយយោងតាមគោលការណ៍សិទ្ធិកុមារ

- ធ្វើសមាហរ័ណកម្មការអប់រំជំនាញបំណិនជីវិតសំរាប់យុវជន ជនជាតិដើមភាគតិច យុវជនពិការ និងការប្រមូលថវិការដ្ឋសំរាប់ការអប់រំក្រៅប្រពន្ធ័

សុខភាពផ្លូវភេទនិងបន្តពូជស្ត្រីនិងសិទ្ធិ

ស្ត្រីនិងកុមារីតែងតែត្រូវបានក្លាយជាកម្មវត្ថុសំរាប់ការរើសអើងនៅជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ច្បាប់ គោលនយោបាយ និងការអនុវត្តិបានបដិសេធពួកគេស្ថានភាពស្មើភាពគ្នាក្នុងសង្គមនិងគ្រប់គ្រងជីវិតរបស់ពួកគេ រូបរាង្គកាយ និងការរស់នៅ។ ទំរង់មួយនៃការរើសអើងគឺការបដិសេធសុខភាពបន្តពូជនិងផ្លូវភេទនិងសិទ្ធិរបស់ពួកគេ។ នេះបញ្ជាក់ថាមានអត្រាស្លាប់មាតាយ៉ាងច្រើនលើសលប់ដែលអាចបង្កាបាននិងការរងរបួសដែលស្ត្រីនិងកុមារីនិងក្រុមផ្សេងទៀត។
មូលហេតុចំលងហ៊ីវស្លាប់យ៉ាងហោចណាស់២០%.

មានការបាន់ប្រមាណថា១.២៧លាននាក់នៃយុវវ័យអាយុពី 15 é 24ឆ្នាំក្នុងតំបន់ទទួលរកនូវការឆ្លងរោគហ៊ីវនេះ។ ប្រហែល៧៥%នៃការឆ្លងមេរោគហ៊ីវទាំងអស់មានទាក់ទងនិងការប្រើប្រាស់ថ្នាំញៀន បុរសរួមភេទជាមួយបុរស ស្ត្រីរកស៊ីផ្លូវភេទក៏ដូចជាអ្នកដែលទិញការរួមភេទនិងបណ្តាលអោយពួកគេប្រឈមមុខនិងការចំលងទៅដៃគូរបស់គេ។ អ្នកដែលមិនពាក់ពន្ធ័ផ្លូវភេទដែលមានការប្រឈមមុខខ្ពស់ជាពិសេសស្ត្រីមេផ្ទះ គួរត្រូវបានចាត់ទុកថាជាក្រុមងាយរងគ្រោះ។

ស្ត្រីនិងកុមារីមានសិទ្ធិទទួលបាននូវស្តង់ការសុខភាពខ្ពស់ដែលអាចទទួលយកបាន។
ពួកគេមានសិទ្ធិក្នុងការបង្ហាញថាតើនិងពេលណាដែលពួកគេចង់មានផ្ទៃពោះតែពួកគេជារឿយៗត្រូវបានបដិសេធមិនផ្តល់អោយនូវសេវាផែនការគ្រួសារ ការពន្យាកំណើតនិងទទួលពត៏មាននិងលទ្ធភាពក្នុងការទទួលនូវការគ្រប់គ្រងរូបកាយផ្ទាល់ខ្លួនរបស់គេ។ ទោះបីជាយ៉ាងណាក៏ដោយការទទួលបានសេវាសុខភាពដោយរួមមានពត៏មានអំពីសុខភាពផ្លូវភេទនិងបន្តពូជនៅតែត្រូវបានគេបដិសេធដោយផ្អែកលើផ្លូវច្បាប់ សេដ្ឋកិច្ចនិងសង្គម

យើងសូមផ្តល់អនុសាសន៍ដល់អាស៊ាននិង/ឬរដ្ឋសមាជិក៖

- ធ្វើសមាហរណ៍កម្មសុខភាពផ្លូវភេទនិងបន្តពូជចូលក្នុងសេចក្តីថ្លែងការស្តីពីសិទ្ធិមនុស្សអាស៊ាន
- អនុវត្តពេញលេញនូវកម្មវិធី ICPD ដែលមានការងារសកម្មភាពជាពិសេសសុខភាពបន្តពូជ ផ្លូវភេទនិងសិទ្ធិមនុស្សក៏ដូចជា ទិសដៅអភិវឌ្ឍន៍សហវត្សទី៥និង៦
- ធានាអោយមានការទៅទទួលបានសុខភាពបន្តពូជនិងផ្លូវភេទដោយផ្អែកលើសិទ្ធិ

- លើយកបញ្ហារំលូតដោយគ្មានសុវត្ថិភាព អត្រាស្លាប់មាតានិងការមានផ្ទៃពោះរបស់យុវវ័យជាសុខភាពសាធារណនិងជាសិទ្ធិមនុស្ស
- ដាក់សុខភាពបន្តពូជនិងផ្លូវភេទជាមួយកម្មវិធីហ៊ីវដើម្បីឆ្លើយតាមនិងអត្រាមរណរបស់សង្គម
- ធានាអោយមានភាពស្មើភាពគ្នាមានតំលៃសំរម្យក្នុងការទទួលនូវសេវាពន្យាកំណើត រំលូលសវត្ថិភាពនិងស្របច្បាប ការថែកូននិងការមិនរើសអើងរួមមានការបញ្ជូន ការមានផ្ទៃពោះ បញ្ហានៃការសំរាល ការបង្ការ ការមានរោគ ការព្យាបាលនិងថែទាំហ៊ីវនិងអេដស៍ហើយការប៉ះពាល់ផ្សេងៗទៀតដោយរួមបញ្ចូលបញ្ហាមនុស្សធម៌
- ធានាអោយមានការការពារមាតុភាពទាំងពលករស្របច្បាប់និងមិនស្របច្បាប់
- ផ្តល់នូវការធ្វើសមាហរណ៍កម្មគ្រប់ជ្រង់ជ្រោយដោយមានការអប់រំអំពីផ្លូវភេទដែលរួមទាំងពត៍មានអំពីសុខភាពបន្តពូជនិងផ្លូវភេទនិងការផ្តល់ប្រឹក្សា
- ធានាថាសុខភាពបន្តពូជនិងផ្លូវភេទនិងសេវាហ៊ីវត្រូវបានផ្តល់ជូនមនុស្សគ្រប់រូបដោយបំពេញតំរូវការផ្សេងៗគ្នានិងភាពជាក់ស្តែងខុសៗគ្នាផងដែរតាមក្រុមអាយុ និន្នការភេទ អត្តសញ្ញាណ យែនឌ័រដែលរួមទាំងចាស់ជរានិង
- លុបបំបាត់របាំងពីសុខភាពបន្តពូជនិងផ្លូវភេទរបស់ស្ត្រីនិងកុមារីដែលដាក់ជីវិតរបស់ពួកគេនិងការរស់នៅប្រកបដោយគ្រោះថ្នាក់និងដកចេញនូវច្បាប់ គោលការណ៍ គោលនយោបាយនិងការអនុវត្តដែលរើសអើង។

សុខភាពបន្តពូជនិងផ្លូវភេទយុវវ័យ

មានគំលាតយ៉ាងពិតប្រាកដក្នុងការទទួលពត៍មានគ្រប់ជ្រុងជ្រោយសំរាប់សុខភាពផ្លូវភេទរបស់មនុស្សវយ័ក្មេង កត្តាចំបងគឺការអនុវត្តច្បាប់គាំទ្រមនុស្សវ័យក្មេងអោយទទួលបានជំរើសក្នុងការអនុវត្តការរួមភេទប្រកដដោយសុវត្ថិភាពខ្ពស់

យើងសូមផ្តល់នូវអនុសាសន៍ដល់អាស៊ាននិង/ឬរដ្ឋសមាជិកថា៖

- ការចាត់អទិភាពពីសកលភាវូបនីយកម្មនៃសុខភាពបន្តពូជនិងផ្លូវភេទនិងសិទ្ធិរបស់យុវវយ័ជាសិទ្ធិមនុស្សជាពិសេសការលើកឡើងពីភាពផ្សេងៗគ្នានៃភេទនិងការកំណត់យែនឌ័រ
- ផ្តល់នូវការអប់រំពីផ្លូវភេទគ្រប់ជ្រុងជ្រោយក្នុងនិងក្រៅសាលានិងសេវារាក់ទាក់ដល់យុវវ័យដោយរួមបញ្ចូលការមានផ្ទៃពោះដែលមិនចង់បាន ការថែទាំមុននិងក្រោយរំលូត ការពន្យាកំណើតបន្ទាន់ ការឆ្លងរោគដែលរួ

មបញ្ចូលហ៊ីវនិងអេដស៍ផងដែរសេវាយុវវ័យគួរតែត្រូវបានលើកដោយមានប្រសិទ្ធិភាព យែនឌ័រ សិទ្ធិដែល ដាក់នូវភាពជឿជាក់ ឥរិយាបទមិនមានយុត្តិធម៌និងជំរើសដ៏ទូលាយតាមបែបទំនើប

- លុបចោលនូវច្បាប់ គោលនយោបាយ និងរបាំងវប្បធម៍ដែលរួមមានការព្រមព្រៀងពីគ្រួសារសំរបមនុស្សវ័យក្មេងជាពិសេសស្ត្រីក្នុងការអនុវត្តិសិទ្ធិរបស់ពួកគេ
- ប្រើប្រាស់នូវភស្តុតាងដោយផ្អែកលើយុទ្ធសាស្ត្រក្នុងការបង្កើតគោលនយោបាយសំរាប់សុខភាពបន្តពូជនិងផ្លូវភេទនិងសិទ្ធិ
- អនុវត្តគំរោងថវិកាក្នុងប្រពន្ធ័ថ្នាក់ជាតិក្នុងការប្រមូលយុវវ័យអោយចូលរួមក្នុងប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់
- ប្រើប្រាស់សិក្ខាសាលាអន្តរជាតិក្នុងការអនុវត្តិនិងរៀបចំសូចនករសកម្មភាពដើម្បីសហគមន៍ក្នុងការចូលរួមប្រមូលទិន្នន័យនិងភស្តុតាងដោយផ្អែកលើការតស៊ូមតិនិងការធ្វើគោលនយោបាយនិង
- ពង្រឹងការអនុវត្តិការឆ្លើយតបមនុស្សធម៍ស្តីពីសុខភាពបន្តពូជនិងផ្លូវភេទនិងសិទ្ធិដែលពាក់ពន្ធ័ជាពិសេសការគ្រប់គ្រងមហន្តរាយពេលដែលមានការចូលរួមនោះត្រូវការយុវវ័យដែលភ្ញាក់រលឹក

ជនពិកា

ផែនការយុទ្ធសាស្រ្តអាស៊ានស្តីពី ការអភិវឌ្ឍន៍សង្គម (2011-2015) បរាជ័យក្នុងការលើពី “ការរើសអើងគ្រប់ផ្នែក” ដូចជាការរើសអើងប្រឆាំងនិងស្ត្រីនិងកុមារដែលជាជនពិការជាលទ្ធផលមនុស្សដែលទទួលផលប៉ះពាល់មានគ្រប់សណ្ឋានក្នុងប្រទេសអាស៊ីអាគ្នេយ៍ដើម្បីការពារ

- ជាបន្តបន្ទាប់ការអនុម័តច្បាប់សេចក្តីប្រកាសពីតួនាទីជនពិការដោយការប្រជុំអាស៊ានខែវិច្ឆិកា២០១១ឥឡូវចាំបាច់ត្រូវធ្វើការសហការគ្នាពីសាខាសុខគ្នាប្រឆាំនិងការរើសអើង។អង្គការសង្គមស៊ីវិលរួមទាំងអង្គការជនពិការអាចចូលរួមនិងផ្តល់នូវការចែករំលែកចំពោះដំណើរការនេះ។ ពួកគេអាចពាំនាំនូវភាពជាក់ស្តែងមកបង្ហាញជូនសហគមន៍អាស៊ាន

យើងសូមផ្តល់អនុសាសន៍ដល់អាស៊ាននិង/ឬរដ្ឋជាសមាជិក៖

- អនុវត្តិអោយបានពេញលេញនូវសន្និសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជិនពិការក្នុងច្បាប់ គោនយោបាយនិងការអនុវត្តិ។ការខិតខំប្រឹងប្រែងគួរតែគ្របដណ្តបលើរូបភាពទាំងឡាយដែលរួមបញ្ចូលនូវការអប់រំ សុខភាពផ្លូវភេទនិងបន្តពូជនិងសិទ្ធិ សុវត្ថិភាពសង្គម ការចូលរួមក្នុងនយោបាយ ការទទួលយកនិងបញ្ជូនពត៏មាន ដែលមិនទាន់បានជំរុញនៅឡើយដែលCRPD គួរធ្វើដោយមិនមានការពន្យាពេលឡើយ

- ត្រួតពិនិត្យការអនុវត្តនិងការចំលងភាពខ្វះចន្លោះដែលមានស្រាប់ជាមួយសរសរទាំងបីរបស់អាស៊ានដែលវេទិការជនពិការអាស៊ាន (ADF) ដើរតួយ៉ាងសំខាន់
- រៀបចំយុទ្ធសាស្រ្តក្នុងការលើកយកគំនិតជនពិការហើយធានាលើកយកពិការភាពមកជជែកក្នុងតំបន់ដោយមានការចូលរួមយ៉ាងសកម្មពី AICHR, ACWC និងសគមន៍ស៊ីវិល
- ធានាថាការជួបពិភាក្សាទល់មុខគ្នាមានការចូលរួមពីជនពិការដែលអនុញ្ញាតិអោយពួកគេអាចបញ្ចេញនូវបញ្ហានិងអនុសាសន៍បាន
- ទទួលស្គាល់នូវតួនាទីស្នូលដែលជនពិការត្រូវតែរៀបចំគំរោង អនុវត្តិ ការត្រួតពិនិត្យនិងវាយតំលៃគោលនយោបាយនៅគ្រប់លំដាប់ថ្នាក់
- ប្រើប្រាស់ ADF ជាវេទិកាសំរាប់ជនពិការដែលអាចលើកឡើងពីបញ្ហាសង្គមទាំងអស់បាននិង
- ធានាការទទួលបាននូវការកសាងនិងបរិយាកាសអំណោយផលសំរាប់ជនពិការអាចចូលរួមយ៉ាងពេញលេញនិងស្មើភាពគ្នាក្នុងបរិយាកាសសង្គមទាំអស់.

៣. ស្ថានភាពនយោបាយ និងសន្តិសុខ

ប្រទេសភូមា/មីយ៉ាន់ម៉ា

ទោះបីជាមានការលើកទឹកចិត្តដល់ការអភិវឌ្ឍក៏ដោយ ក៏ប្រទេសភូមា/មីយ៉ាន់ម៉ានៅតែជាប្រទេសដែលមានការរំលោភសិទ្ធិមនុស្សជាលក្ខណ:ប្រព័ន្ធ និងរីករាលដាល ដែលអាចបង្កើតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ព្រមទាំងគ្មានការបើកទូលាយ និងសេរីភាពនយោបាយនៅឡើយទេ។ ការចរចាថ្មីៗរវាងរដ្ឋាភិបាលនិងក្រុមប្រដាប់អាវុធជនជាតិភាគតិចមិនទាន់បញ្ចប់ជម្លោះប្រដាប់អាវុធ និងការវាយប្រហារប្រឆាំងជនស៊ីវិលជនជាតិភាគតិច ព្រមទាំងបង្កើត IDP អោយបានចំនួនច្រើនផងដែរ។ ការសម្រួលការរិះគន់តាមប្រព័ន្ធផ្សព្វផ្សាយមិនទាន់មានជាកំណែទម្រង់ច្បាប់ ច្បាប់ដាក់គំនាបនៅតែមានចំពោះការផ្សព្វផ្សាយនានា ហើយអ្នកទោសនយោបាយនៅតែជាប់នៅក្នុងពន្ធនាគារនៅឡើយ។ ប្រជាជននៅតែមានការភ័យខ្លាចចពោះការចាប់ខ្លួនដោយសារសកម្មភាពនយោបាយ ដូចនេះគឺជាដាក់កម្រិតចំពោះសមត្ថភាពចូលរួមដោយសេរីនៅក្នុងជីវិតឯកជន។

ដូច្នេះ តំណែងជាប្រធានរបស់ប្រទេសភូមា/មីយ៉ាន់ម៉ានៅក្នុងឆ្នាំ២០១៤ ទំនងជាជួបនឹងឧបសគ្គនៅក្នុងការផ្តល់ការបើកទូលាយដល់ប្រជាជនភូមា/មីយ៉ាន់ម៉ា និងសង្គមស៊ីវិលឯករាជ្យក្នុងតំបន់ដើម្បីប្រមូល ក៏ដូចជាលើកយកកង្វល់របស់ប្រជាជនទៅប្រាប់ទៅដល់អ្នកដឹកនាំអាស៊ាន។

យើងសូមផ្តល់មតិដល់អាស៊ាន និង/ឬរដ្ឋសមាជិករបស់ខ្លួនអោយ៖

- ការគោរពសិទ្ធិសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំរបស់សង្គមស៊ីវិលឯករាជ្យ និងប្រជាជនអាស៊ាន
- លើកកម្ពស់សហគមន៍អាស៊ានដែលផ្តោតលើប្រជាជន និងការចូលរួមដោយសេរី និងផុលផុសរបស់ប្រជាជនភូមា/ មីយ៉ាន់ម៉ា និងសង្គមស៊ីវិលក្នុងតំបន់នៅក្នុងដំណើរការកសាងសហគមន៍របស់អាស៊ាននៅក្នុងអាណត្តិជាប្រធានរបស់ប្រទេសភូមា/មីយ៉ាន់ម៉ាក្នុងឆ្នាំ២០១៤។
- ជំរុញអាជ្ញាធរប្រទេសភូមា/មីយ៉ាន់ម៉ាអោយ៖
  - ដោះលែង និងធ្វើនីតិសម្បទាអ្នកទោសនយោបាយទាំងអស់ដោយគ្មានលក្ខខណ្ឌ
  - ឈានដល់បទឈប់បាញ់ទូទាំងប្រទេសដែលដោះស្រាយដើមចមនៃជម្លោះជាមួយក្រុមប្រដាប់អាវុធជនជាតិភាគតិច
  - ដោះស្រាយបញ្ហាការពិត និងគណនេយ្យភាពលើការរំលោភសិទ្ធិមនុស្ស និងបញ្ចប់ វប្បធម៌និទណ្ឌភាព និង
  - ធ្វើវិសោធនកម្ម ឬលុបចោលច្បាប់ដាក់កំហិតសិទ្ធិមនុស្សលើប្រជាជនភូមា/មីយ៉ាន់ម៉ា ដើម្បីធានាការចូលរួមដោយសេរី និងផុលផុសរបស់ប្រជាជននៅក្នុងដំណើរការ អន្តរកាល។

សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សរបស់អាស៊ាន

យើងមានការខកចិត្តយ៉ាងខ្លាំងចំពោះដំណើរការធ្វើសេចក្តីព្រាងដោយសម្ងាត់ មិនបើកចំហរ និងគ្មានតម្លាភាពនៃសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សរបស់អាស៊ាន (AHRD)។ គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) បានខកខានក្នុងការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលអាស៊ានអោយបានទូលំទូលាយនៅក្នុងកម្រិតថ្នាក់តំបន់ ហើយមានតំណាងតិចតួចប៉ុណ្ណោះដែលបានពិគ្រោះយោបល់នៅកម្រិតថ្នាក់ជាតិ។ សេចក្តីព្រាងដែលបានបង្កើតឡើងដោយក្រុមធ្វើសេចក្តីព្រាងកាលពីខែមករា មិនទាន់បានផ្សព្វផ្សាយនៅឡើយទេ។ អនុបេសកកម្ម CSO ត្រូវបានទុកចោលដោយពុំទទួលចម្លើយឡើយ ដែលនាំអោយ CSO នៅតែមិនដឹងអំពីថាតើធាតុចូលរបស់ខ្លួនត្រូវបានយកទៅពិចារណាឬដូចម្តេចឡើយ។

ជាពិសេស ឯកសារព្រាងដែលមិនទាន់បានបោះពុម្ពជាផ្លូវការ បានលាតត្រដាងអំពីនិន្នាការព្រួយបារម្ភក្នុងចំណោមអ្នកធ្វើសេចក្តីព្រាងដែលនឹងផ្តល់ដល់ប្រជាជនអាស៊ាននូវការការពារ សិទ្ធិមនុស្សក្នុងកម្រិតទាបជាងលិខិតូករសកល ឬថ្នាក់តំបន់ផ្សេងៗទៀត ប្រសិនបើមានការផ្សព្វផ្សាយ។ មានការសង្កត់ធ្ងន់ទៅលើទស្សនទានដូចជាភារកិច្ច អត្តសញ្ញាណជាតិ និងតំបន់ និងគ្មានការលូកដៃ ដែលទាំងអស់នេះអាចរងការរំលោភដើម្បីធ្វើអោយការរំលោភសិទ្ធិមនុស្សក្លាយជាស្របច្បាប់។ បច្ចេកស័ព្ទដ៏ចម្រូងចម្រាស់ដូចជា “ពលរដ្ឋល្អ” និង

"សីលធម៌សាធារណៈ" អាចបើកទ្វារចំពោះការបកស្រាយដែលរំលោភ និងមានការរើសអើង ជាពិសេសពាក់ព័ន្ធនឹងស្ត្រី ប្រជាជន LGBTIQ កុមារ ប្រជាជនអន្តោប្រវេសន៍ និងជនជាតិភាគតិច ព្រមទាំងក្រុមដែលមិនត្រូវបានយកចិត្តទុកដាក់ជាទូទៅផ្សេងៗទៀតផងដែរ។ បទប្បញ្ញត្តិជាច្រើនសម្រាប់សិទ្ធិជាក់លាក់មានលក្ខណៈមិនគ្រប់គ្រាន់ មិនទប់ស្កាត់ការរំលោភ ឬបទប្បញ្ញត្តិផ្សេងៗទៀតមានបាត់សមាសធាតុសំខាន់ៗ។ ដូចនេះ សេរីភាពបញ្ចេញមតិ និងប្រមូលផ្តុំ សេរីភាពប្រជាជន LGBTIQ ពីការរើសអើង និងសិទ្ធិយេនឌ័រមិនទាន់ចែងច្បាស់នៅឡើយទេ។

យើងសូមផ្តល់មតិដល់ AICHR អាស៊ាន និង/ឬរដ្ឋសមាជិករបស់ខ្លួនអោយ៖

- ផ្សព្វផ្សាយជាបន្ទាន់នូវសេចក្តីព្រាង AHRD ចុងក្រោយបំផុត ដើម្បីអោយសង្គមស៊ីវិលអាចចូលរួមដោយទូលំទូលាយនៅក្នុងដំណើរការធ្វើសេចក្តីព្រាង
- បន្ត និងពង្រឹកការពិគ្រោះយោបល់សំខាន់ៗនៅកម្រិតថ្នាក់ជាតិ ជាពិសេសពីសំណាក់តំណាង របស់ AICHR ដែលមិនទាន់បានអនុវត្តកិច្ចការនេះនៅឡើយ
- ធ្វើការពិគ្រោះយោបល់អោយបានទូលំទូលាយ និងបើកចំហរ ទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ តំបន់ ដែលក្នុងពេលនោះ គួរលើកយកសេចក្តីព្រាងចុងក្រោយបំផុតមកពិភាក្សា។ AICHR គួរពិចារណាអោយបានម៉ត់ចត់លើរបាយការណ៍ពី CSO វិទ្យាស្ថានជាតិសិទ្ធិមនុស្ស និងភាគីពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងផ្តល់មតិត្រឡប់ដល់អ្នកទាំងនោះវិញផងដែរ
- បកប្រែសេចក្តីព្រាង AHRD ទៅជាភាសាជាតិរបស់ខ្លួន និងភាសាតាមតំបន់ផ្សេងៗទៀតនៃប្រទេសអាស៊ានដើម្បីលើកទឹកចិត្តអោយមានការចូលរួមកាន់តែទូលំទូលាយពីសាធារណៈជន នៅក្នុងតំបន់។ និង
- ពាក់ព័ន្ធនឹងទស្សនៈវិស័យអំពីសិទ្ធិមនុស្សរបស់ស្ត្រី
  - AHRD ផ្តល់លទ្ធភាពអោយស្ត្រីទទួលបានយុត្តិធម៌នៅក្នុងតំបន់អាស៊ីអាគ្នេយ៍
  - រដ្ឋាភិបាលអាស៊ានចាត់គ្រប់វិធានការសមស្របទាំងអស់ដើម្បីកែសម្រួល ឬលុបចោល ច្បាប់ បទប្បញ្ញត្តិ វប្បធម៌ និងទម្លាប់ទាំងឡាយដែលដាក់កម្រិតស្ត្រីមិនអោយប្រើប្រាស់ សេរីភាព និងសិទ្ធិមូលដ្ឋានរបស់ខ្លួន
  - ទស្សនៈវិស័យអំពីសិទ្ធិមនុស្សរបស់ស្ត្រី ដែលបានឆ្លុះបញ្ចាំងនៅក្នុង CEDAW និង សេចក្តីប្រកាសទីក្រុងវីយែន និងកម្មវិធីសកម្មភាព ត្រូវតែរួមបញ្ចូលទៅក្នុង AHRD

- ពុំមានការកាត់បន្ថយសិទ្ធិនៅក្នុង AHRD និងគ្មានការដាក់បញ្ចូលខស្តីពី "សីលធម៌ និងគុណតម្លៃនៃសីលធម៌ ឬគុណតម្លៃប្រពៃណី" ដែលប្រើប្រាស់ដើម្បីកាត់បន្ថយសិទ្ធិ ។ និង
- ដំណើរការធ្វើសេចក្តីព្រាង AHRD ត្រូវតែមានការពិគ្រោះយោបល់ជាសាធារណៈ និង ត្រូវតែមានការចូលរួមពីស្ត្រី។

ប្រជាធិបតេយ្យ និងការបោះឆ្នោត

បញ្ហាប្រឈមសំខាន់ៗចំពោះការសម្រេចអោយបាននូវក្របខ័ណ្ឌប្រជាធិបតេយ្យរួមមាន៖ ប្រព័ន្ធបោះឆ្នោត ជាពិសេស រូបមន្តបែងចែកអសនៈ រដ្ឋបាលបោះឆ្នោត ដំណោះស្រាយវិវាទបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត យុត្តិធម៌ការបោះឆ្នោត សង្កេតការណ៍បោះឆ្នោត សមភាពបោះឆ្នោត និងសមភាពយេនឌ័រ លទ្ធចូលរួមដោយស្មើភាពសម្រាប់ជនពិការ និងជនងាយរងគ្រោះដទៃផ្សេងទៀត ការផ្តល់ហិរញ្ញប្បទានដល់គណៈបក្ស និងយុទ្ធនាការឃោសនាបោះឆ្នោត ការប្រកាសដោយតម្លាភាពអំពីទ្រព្យសម្បត្តិរបស់អ្នកនយោបាយ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយស្មើភាព និងសមធម៌ យោធា នគរបាល និងអព្យាក្រិតភាពមន្ត្រីរាជការ ការប្រើប្រាស់ធនធានរបស់ រដ្ឋ ជម្លោះពាក់ព័ន្ធការបោះឆ្នោត និងការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងការបោះឆ្នោត។

ដោយពិចារណាទៅផែនការអាស៊ានដើម្បីប្រជាធិបតេយ្យ និងការបោះឆ្នោតដោយសេរី និងយុត្តិធម៌ដែលបង្កើតឡើងដោយបណ្តាញដើម្បីការបោះឆ្នោតដោយសេរី (ANFREL) និងសេចក្តីប្រកាសទីក្រុងហ្សាកាតាស្តីពីសហគមន៍បោះឆ្នោតដែលគាំទ្រដោយវេទិកាអង្គភាពគ្រប់គ្រងការបោះឆ្នោតអាស៊ាន យើងសូមផ្តល់មតិដល់ អាស៊ាន និង/ឬរដ្ឋសមាជិករបស់ខ្លួន ដែលមិនទាន់បានអនុវត្តកិច្ចការនេះ៖

- ផ្តល់សច្ចាប័នដល់អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងនយោបាយ
- ចូលរួមសហភាពសភាអន្តរជាតិ (IPU) និងគោរពតាមបទដ្ឋានរបស់ IPU ដើម្បីរៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌

អាស៊ាន និង/ឬរដ្ឋសមាជិករបស់ខ្លួនត្រូវ៖

- ដាក់បញ្ចូលសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សទៅក្នុងក្របខ័ណ្ឌជាតិនៃរដ្ឋសមាជិក នីមួយៗ ដើម្បីបង្កើតបរិយាកាសសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌
- បង្កើតអង្គភាពបោះឆ្នោតឯករាជ្យដើម្បីធានាបរិយាកាសអព្យាក្រិត្យ និងយល់ពីគោលដៅសម្រាប់រៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌

- បន្តប្រយុទ្ធប្រឆាំងអនក្ខរភាព និងដាក់អោយប្រើប្រាស់កម្មវិធីជាក់លាក់ស្តីពីនយោបាយ និង សិទ្ធិមនុស្សនៅក្នុងប្រព័ន្ធអប់រំដើម្បីបង្កើតការយល់ដឹងរបស់ពលរដ្ឋអំពីសិទ្ធិរបស់ខ្លួននៅក្នុង ការចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ

អាស៊ាន និង/ឬរដ្ឋសមាជិករបស់ខ្លួន សង្គមស៊ីវិល និងគណៈបក្សនយោបាយត្រូវ៖

- រៀនសូត្របទពិសោធន៍ពីគ្នាទៅវិញទៅមកនៅក្នុងរៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌

ការកសាងសន្តិភាព

បណ្តាប្រទេសជាច្រើននៅក្នុងតំបន់អាស៊ានមានប្រវត្តិស្ថិតក្រោមអាណានិគមន៍បរទេស និងជម្លោះប្រដាប់អាវុធ ទាំងខាងក្នុង និងខាងក្រៅ។ នៅពេលទទួលបានឯករាជ្យ និងសន្តិភាព បណ្តាប្រទេសអាស៊ានបានព្យាយាម កសាងអត្តសញ្ញាណ និងរចនាសម្ព័ន្ធសង្គម និងនយោបាយរបស់ខ្លួន ប៉ុន្តែ កិច្ចការនេះតែងតែអមដោយភាពតាន តឹងផ្ទៃក្នុង អន្តរគមន៍ពីខាងក្រៅ និងរបបកៀបសង្កត់។ នៅក្នុងបណ្តាប្រទេសជាច្រើន អំពើហិង្សា និងជម្លោះ ផ្ទៃក្នុងបន្តរហូតមកដល់សព្វថ្ងៃ។ ទោះបីជារដ្ឋអាស៊ានបានប្តេជ្ញារក្សាប្រជាធិបតេយ្យ និងដំណោះស្រាយជម្លោះ ដោយសន្តិវិធី ប្រជាជនអាស៊ានមានបទពិសោធន៍ខុសៗគ្នានៅក្នុងការកសាងសន្តិភាពនៅក្នុងប្រទេសនីមួយៗ។

យើងសូមផ្តល់មតិដល់ អាស៊ាន និង/ឬរដ្ឋសមាជិករបស់ខ្លួនអោយ៖

- បង្កើតប្រវត្តិនៃការផ្តោតលើប្រជាជន នៃតំបន់អាស៊ីអាគ្នេយ៍ ដោយមានការចូលរួមយ៉ាង ផុសផុលពីសំណាក់ប្រជាជន
- ធ្វើអោយសម្រេចនូវកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាលើប្រជាធិបតេយ្យភាវូបនីយកម្ម ការកសាង សន្តិភាព និងការបញ្ចប់ជម្លោះដោយមានការចូលរួមយ៉ាងផុលផុសពីសំណាក់ប្រជាជននៅក្នុង ដំណើរការទាំងមូល
- លើកកម្ពស់ការយោគយល់គ្នាក្នុងចំណោមប្រជាជន និងផ្តល់ការបើកទូលាយសម្រាប់ការផ្លាស់ ប្តូរយោបល់រវាងប្រជាជន និងប្រជាជន និងកិច្ចពិភាក្សាសន្តិភាពនៅគ្រប់ពេលវេលាទាំងអស់
- បង្កើត និងគាំទ្រយ៉ាងពេញទំហឹងចំពោះស្ថាប័នអាស៊ានសម្រាប់ការផ្សះផ្សារសន្តិភាពដែល ដឹកនាំដោយប្រជាជនសុទ្ធសាធ
- យោគយល់ និងបើកទូលាយជាងមុន ព្រមទាំងដោះស្រាយរាល់បញ្ហាទាំងអស់ដោយសន្តិវិធី ពាក់ព័ន្ធជម្លោះព្រំដែនទាំងអស់
- បញ្ចូល “សិទ្ធិទទួលបានសន្តិភាព” ទៅក្នុងសេចក្តីប្រកាសរបស់អាស៊ានស្តីពីសិទ្ធិមនុស្ស។
- បែងចែកធនធានដោយសប្បុរសសម្រាប់ការអប់រំសន្តិភាពនៅគ្រប់កម្រិត និងគ្រប់ប្រភេទនៃ ការអប់រំ

- ពិចារណាការបញ្ចូលប្រទេសទីម័រជាសមាជិកអាស៊ាននៅឆ្នាំ២០១២
- យន្តការអាស៊ានចំពោះស្ថានភាពជម្លោះនៅក្នុងតំបន់អាស៊ីអាគ្នេយ៍
- ឆ្នាំ២០១៣ ជាឆ្នាំពិនិត្យលើកទីមួយលើធម្មនុញ្ញអាស៊ាន រយៈពេលប្រាំឆ្នាំបន្ទាប់ពីអនុម័ត ប៉ុន្តែនៅឆ្នាំ២០១២ រដ្ឋអាស៊ានបួនក្នុងចំណោមដប់ រួមមានប្រទេសថៃ និងភូមា/មីយ៉ាន់ម៉ា ជួបប្រទះនូវជម្លោះប្រដាប់អាវុធផ្ទៃក្នុង
- អាស៊ានមានលិខិតូបករ និងយន្តការជាច្រើនដែលអាចប្រើប្រាស់ដើម្បីដោះស្រាយស្ថានភាព ជម្លោះដូចជាកិច្ចព្រមព្រៀងកោះបាលី II ឆ្នាំ២០១៣ ធម្មនុញ្ញអាស៊ាន ព្រមទាំងសរសស្តម្ភអាស៊ានទាំងបីផងដែរ។ ដោយសារនឹងមានការពិនិត្យលើធម្មនុញ្ញអាស៊ាន នោះគឺជាពេលសមស្របដែលត្រូវវាយតម្លៃថាតើយន្តការបច្ចុប្បន្នបានឆ្លើយតបចំពោះជម្លោះនៅក្នុងតំបន់បានកម្រិតណា នៅមុនពេលស្នើអោយមានយន្តការ និងលិខិតូបករថ្មី។

យើងសូមផ្តល់មតិដល់ អាស៊ាន និង/ឬ រដ្ឋសមាជិករបស់ខ្លួនអោយ៖

- ប្រកាន់ខ្ជាប់ចំពោះច្បាប់អន្តរជាតិ និងបញ្ឈប់ការប្រើប្រាស់កម្លាំងប្រដាប់អាវុធដើម្បីដោះស្រាយជម្លោះរបស់ខ្លួន
- ធានាអោយមានអាស៊ានឯករាជ្យ អធិបតេយ្យភាព យុត្តិធម៌ ប្រជាធិបតេយ្យ និងសន្តិភាព
- ពិនិត្យលើគ្រប់កិច្ចសហប្រតិបត្តិការ ឬកិច្ចព្រមព្រៀងផ្នែកយោធាទាំងអស់ជាមួយសហរដ្ឋអាមេរិក
- ដោះស្រាយបញ្ហាមូលដ្ឋាន និងមូលដ្ឋានគ្រឹះ ដូចជាភាពក្រីក្រ ការរំលោភសិទ្ធិមនុស្ស ការបង្ក្រាបយោធានិយមដែលជាមូលហេតុនៃជម្លោះប្រដាប់អាវុធផ្ទៃក្នុងនៅក្នុងតំបន់អាស៊ាន
- ធានាការការពារប្រជាជន ស្ត្រី និងកុមារពីជម្លោះយោធា
- លើកកម្ពស់ការយល់ដឹងពីសិទ្ធិមនុស្ស និងអនុសញ្ញារបស់អង្គការសហប្រជាជាតិក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាល
- បង្កើតក្រុមប្រឹក្សាផ្សះផ្សារ និងស្ថាប័នមជ្ឈិតកម្មដើម្បីដោះស្រាយជម្លោះរវាងបណ្តារដ្ឋអាស៊ាន
- ពិនិត្យមើលជាបន្ទាន់លើស្ថានភាពស្ត្រីនៅក្នុងតំបន់រងគ្រោះដោយសារជម្លោះ ជាពិសេស អំពើហិង្សាយេនឌ័រ និងផ្លូវភេទដែលបានប្រព្រឹត្តនៅក្នុងសហគមន៍ជនជាតិភាគតិច ដូចនៅក្នុងករណីប្រទេសភូមា/មីយ៉ាន់ម៉ា

យើងសូមផ្តល់មតិអោយគណៈកម្មការអាស៊ានលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC)៖

- សម្របសម្រួលការបញ្ជ្រាប CEDAW និង UNSCR 1325 ក្នុងចំណោមរដ្ឋអាស៊ាន
- រៀបចំការបណ្តុះបណ្តាលផ្តោតលើយេនឌ័រសម្រាប់មន្ត្រី និងសមាជិកបុគ្គលិកនៃនាយកដ្ឋាន គណៈកម្មការ វិទ្យាស្ថាន និងក្រុមប្រឹក្សាអាស៊ានទាំងអស់ លេខាធិការដ្ឋាន ព្រមទាំងការអង្គភាពបណ្តុះបណ្តាលផ្សេងៗទៀតផងដែរ។
- ចេញអនុស្សរណៈដល់រដ្ឋាភិបាលអាស៊ានទាំងអស់ដើម្បីអនុវត្តបទប្បញ្ញត្តិនៃ UNSCR 1325 និងជំរុញរដ្ឋាភិបាលអោយបង្កើតផែនការសកម្មភាពជាតិ
- ដាក់បញ្ចូលទៅក្នុងផែនការការងាររបស់ខ្លួននូវរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ព្រមទាំងអញ្ជើញអង្គការសង្គមស៊ីវិលអោយចូលរួមនៅក្នុងការបង្កើត អនុវត្ត តាមដាន និង វាយតម្លៃផែនការការងារស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ
- ធានាវត្តមាន និងតួនាទីសកម្មរបស់ស្ត្រី និងអង្គការសន្តិភាពនៅក្នុងការពិគ្រោះ និងកិច្ចប្រជុំពិភាក្សាជាកាលិករបស់ ACWC ។

**ចប់**

**JOINT STATEMENT OF THE 2012 ASEAN CIVIL SOCIETY CONFERENCE / ASEAN PEOPLES' FORUM**

**31 March 2012**
**Phnom Penh, Cambodia**

**Preamble**

We, more than 1,200 delegates representing various civil society organizations and movements of workers from rural and urban sectors as well as the migrant sector, peasants and farmers, women, children, youth, the elderly, persons with disabilities, urban poor, Indigenous Peoples, victims of human rights violations, domestic workers, lesbian gay transgender/transsexual intersex and queer (LGBTIQ) people, human rights defenders and other groups, gathered together in Phnom Penh for the 2012 ASEAN Civil Society Conference / Peoples' Forum (ACSC/APF) on 29-31 March 2012, to discuss issues under the theme "Transforming ASEAN into a People Centered Community".

We reaffirm our commitment to ensure that ASEAN upholds the fundamental principles of democracy, rule of law, human rights and dignity, good governance, the best interests of the child, meaningful, substantive and inclusive people's participation and sustainable development in the pursuit of economic, social, gender and ecological justice and development so as to bring peace and prosperity to the ASEAN region.

We express serious concerns over the fact that since 2005, the ASEAN Civil Society Conference has been submitting extensive recommendations to ASEAN leaders and that not much progress has been made. Therefore, we reiterate our recommendations from the 2011 Forum and call on the ASEAN leaders to take positive actions promptly to implement them.

We reiterate that the people's participation and a truly people-centered ASEAN is an essential part of the ASEAN community building. The growing awareness of ASEAN and its meetings and institutions by the region's people is encouraging. However, we note with deep disappointment that during the ACSC/APF unacceptable restrictions were imposed on participants' human rights to freedom of expression and assembly. Certain participants were actively discouraged from attending the ACSC/APF, and workshops on land rights and on Burma/Myanmar were not allowed to take place.

We urge ASEAN leaders to ensure people's participation and a people-centered ASEAN during 2012, as well as in Brunei in 2013 and Burma/Myanmar in 2014.

We deeply appreciate and commend the efforts of the organizers of the ACSC/APF in Cambodia who ensured a robust and independent ACSC/APF and present this statement of key issues and recommendations to the 20th ASEAN Summit in Cambodia.

## 1. ECONOMIC AND ENVIRONMENT

**Land Rights**

Many land deals gravely violate human rights, ignoring adverse impacts on society, local economies and the environment. In most cases, people who live on or make a living from that land are not consulted, treated fairly or properly compensated.

Many land deals involve forced evictions, destruction of livelihoods, and conflicts between locals and investors, some of which have continued for years. In the rush for land by local powerful elites and foreign investors, many families, and sometimes whole communities, are losing their homes and the land they rely on to grow enough food to eat and make a living.

In addition to losing their land and livelihoods, members of affected communities who struggle to protect their homes and livelihoods continue to face court cases filed by powerful investors. Government authorities and judicial systems often fail to protect the interest of the people, working instead in favour of powerful investors.

We urge ASEAN and/or its member states:

- Immediately end land grabs, forced evictions and violence against their people who are exercising their basic human rights to their land, homes and livelihoods;
- Speed up the process to improve tenure security for citizens and must prioritize protecting the land and livelihoods of their own citizens, rather than pandering to investors;
- Respect all existing land use rights, irrespective of whether or not legal titles or formal ownership rights exist. This includes lands owned and managed by community, and lands owned by indigenous people or others who have been farming and living on the land for generations but do not have legal documents confirming ownership;
- Solve land disputes between local communities and powerful investors urgently and fairly;
- Ensure that infrastructure, including education and healthcare facilities and job opportunities is in place before sending people to new locations.

**Climate change – impact on Indigenous Peoples and forest dependent communities**

People in ASEAN, especially forest dependent and indigenous communities, women and children are directly, significantly and adversely impacted by climate change. ASEAN governments are beginning to engage actively in the international negotiations for the promotion of the Reducing Emissions from Deforestation and forest Degradation (REDD+ mechanism as incentive for conservation and sustainable management of the forest and biodiversity. However, this process would be counterproductive if it excludes indigenous communities and forest dependent in the REDD+ decision-making at all levels. Moreover, REDD+ as applied in some ASEAN countries is marred by governance problems including corruption, cronyism and human rights violations, including by the military.

Other risks include failure to adequately safeguard the right of Indigenous People to free prior and informed consent (FPIC), secure tenure and livelihood Insufficient information at the local level and limited capacity and awareness about the REDD+ mechanism.

We recommend that ASEAN and/or its member states:

- Honour their duty to serve the interest of their peoples affected by REDD+, which includes the protection of community forests, traditionally-owned land, forests and natural resources;

- Provide an opportunity and support to civil society organizations to fully engage in the consultation, decision- making and implementation of the REDD+ process;
